ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ
# ស្តីពី
# ដំណើរការនៃការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា


សហការផលិតដោយៈ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

# តារាងមាតិកា

អក្សរកាត់ ........ 6

អារម្ភកថា ........ 7

មូលដ្ឋានច្បាប់........ 9

ដំណាក់កាលទី១៖........ 12

ក្រសួងអភិវឌ្ឍន៍ជនបទ៖ ការកំណត់អត្តសញ្ញាណ សហគមន៍ជនជាតិដើមភាគតិច ........ 12

សេចក្តីផ្តើម........ 13

ជំហានទី ១៖ ធ្វើការផ្សព្វផ្សាយការយល់ដឹងនៅក្នុងចំណោមអាជ្ញាធរថ្នាក់ខេត្ត (មន្ទីរជំនាញពាក់ព័ន្ធ) ស្រុក ឃុំ ភូមិ និងសហគមន៍ជនជាតិដើមភាគតិច ........ 13

ជំហានទី២៖ សហគមន៍ជនជាតិដើមភាគតិចបង្ហាញឆន្ទៈក្នុងការចាប់ផ្តើមដំណើរការកំណត់អត្តសញ្ញាណ សហគមន៍ជនជាតិដើមភាគតិច ........ 14

ជំហានទី៣ ៖ ធ្វើការផ្សព្វផ្សាយដល់សហគមន៍គោលដៅ ........ 14

ជំហានទី៤ ៖ សហគមន៍ជនជាតិដើមភាគតិចបោះឆ្នោតជ្រើសរើសតំណាង គណៈកម្មាធិការសហគមន៍ និង ស្វ័យអត្តសញ្ញាណខ្លួនជា "ជនជាតិដើមភាគតិច" ........ 16

ជំហានទី៥ ៖ ការដាក់ពាក្យ ការវាយតម្លៃ និងទទួលស្គាល់អត្តសញ្ញាណសហគមន៍ ជនជាតិដើមភាគតិច របស់សហគមន៍ជនជាតិដើមភាគតិច ........ 17

ការដាក់ពាក្យស្នើសុំរបស់សហគមន៍ជនជាតិដើមភាគតិច ........ 17

ក្រសួងអភិវឌ្ឍន៍ជនបទទទួលស្គាល់សហគមន៍ជា "ជនជាតិដើមភាគតិច" ........ 18

ដំណាក់កាលទី២៖ ........ 20

ក្រសួងមហាផ្ទៃ ការចុះបញ្ជីទទួលស្គាល់ជាផ្លូវការ សហគមន៍ជនជាតិដើមភាគតិច ដើម្បីទទួលបាននូវសិទ្ធិជា "នីតិបុគ្គល" សេចក្តីផ្តើម ........ 20

អំពីសកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្ត៖ ........ 21

ជំហានទី១ ៖ អំពីការរៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងរៀបចំសមាសភាពគណៈកម្មាធិការ សហគមន៍........ 22

ជំហានទី២ ៖ អំពីការពិនិត្យគោលបំណង និងឆន្ទៈរបស់សមាជិកសហគមន៍........ 22

ជំហានទី៣ ៖ អំពីការរៀបចំកិច្ចប្រជុំពេញអង្គដើម្បីសម្រេចអនុម័ត សេចក្តីព្រាងលក្ខន្តិកៈ និងការជ្រើសតាំង គណៈកម្មាធិការសហគមន៍........ 23

ជំហានទី៤ ៖ អំពីការរៀបចំពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ជាផ្លូវការ ........ 24

ជំហានទី៥ ៖ អំពីការចុះបញ្ជីទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជា(នីតិបុគ្គល) ........ 24

ដំណាក់កាលទី២.៥៖........ 26

សហាគមន៍ជនជាតិដើមភាគតិច ដាក់ពាក្យសុំចុះបញ្ជី ដីកម្មសិទ្ធិសមូហភាពទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..... 26

សេចក្តីផ្តើម ..... 27

ជំហានទី១ ៖ សហាគមន៍ជនជាតិដើមភាគតិច រៀបចំតាក់តែងបទបញ្ជាផ្ទៃក្នុង ..... 28

ជំហានទី២ ៖ ការប្រមូលទិន្នន័យ និងផលិតផែនទីបឋមដោយកំណត់ព្រំប្រទល់ ប្រភេទដីរបស់សហាគមន៍ .... 29

ខ. ផែនទីបឋម ..... 30

ជំហានទី៣ ៖ សហាគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំចុះបញ្ជីដីសមូហភាពទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..... 32

ដំណាក់កាលទី៣៖ ..... 34

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វាស់វែង បិទផ្សាយ អនុបយោគ ដើម្បីចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពជូន សហាគមន៍ជនជាតិដើមភាគតិច ..... 34

សេចក្តីផ្តើម ..... 35

១) ក្រុមការងារចុះបញ្ជីដីសហាគមន៍ជនជាតិដើមភាគតិច ..... 35

២) សមាសភាពអ្នកពាក់ព័ន្ធក្នុងការងារចុះបញ្ជីដីសហាគមន៍ជនជាតិដើមភាគតិច ..... 35

៣) ដំណើរការនៃការចុះបញ្ជីដីសហាគមន៍ជនជាតិដើមភាគតិច៖ ..... 36

៤) ការដាក់ពាក្យសុំចុះបញ្ជីដីសហាគមន៍ជនជាតិដើមភាគតិច ..... 37

៥) ការងារវាស់វែង ..... 37

៦) ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ..... 38

ករណីមិនមានការឯកភាពពីអ្នកជិតខាង ឬអាជ្ញាធរដ្ឋបាល ..... 38

៧)ការប្រជុំ និងសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយជាមួយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ..... 39

៨) ការធ្វើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ..... 39

៩) ការចេញប័ណ្ណកម្មសិទ្ធិ ..... 39

ឧបសម្ព័ន្ធ ..... 41

ឧបសម្ព័ន្ធទី១៖ ក្រសួងអភិវឌ្ឍន៍ជនបទ "ការកំណត់អត្តសញ្ញាណសហាគមន៍ ជនជាតិដើមភាគតិច" ..... 42

ទម្រង់គំរូទី១៖ គំរូលិខិតរបស់ក្រសួងអភិវឌ្ឍន៍ជនបទផ្ញើជូនអភិបាលនៃគណៈអភិបាលខេត្តដើម្បីជម្រាបជូនអំពីដំណើរការនៃការចុះបញ្ជីដីសមូហភាពនឹងប្រព្រឹត្តឡើងក្នុងដែនដីរបស់លោក ..... 43

ទម្រង់គំរូទី២៖ កំណត់ហេតុប្រជុំពិគ្រោះយោបល់ ..... 44

ទម្រង់គំរូទី៣៖ ប្រកាសស្ទ័យអត្តសញ្ញាណសហាគមន៍ជនជាតិដើមភាគតិច ..... 47

ទម្រង់គំរូទី៤ ៖ ពាក្យសុំចូលជាសមាជិកសហាគមន៍ ..... 49

ទម្រង់គំរូទី៥៖ស្នាមផ្តិតមេដៃ នៃសមាជិកគ្រួសារទាំងអស់របស់សហាគមន៍ ..... 51

ទម្រង់គំរូទី៦ ៖ ពាក្យសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ..... 53
ទម្រង់គំរូទី៧៖ គំរូលិខិតស្នើសុំការកំណត់អត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិចដែលអភិបាលនៃគណៈអភិបាលខេត្តផ្ញើជូនរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ..... 55
ទម្រង់គំរូទី៨៖ លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ..... 56
ឧបសម្ព័ន្ធទី២៖ ..... 57
ទម្រង់គំរូ ..... 57
ឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីជា "នីតិបុគ្គល" ..... 57
ទម្រង់គំរូទី៩៖ គំរូពង្រាងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច ..... 58
ទម្រង់គំរូទី១០៖គំរូលិខិតសហគមន៍ជនជាតិដើមភាគតិចស្នើសុំអភិបាលនៃគណៈអភិបាលដើម្បីរៀបចំកិច្ចប្រជុំសហគមន៍ ..... 70
ទម្រង់គំរូទី១១៖ គំរូសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ទទួលស្គាល់លក្ខន្តិកៈសហគមន៍ ..... 71
ទម្រង់គំរូទី១២៖ គំរូសំណើរសុំក្រុមប្រឹក្សាឃុំ/សង្កាត់ទទួលស្គាល់លក្ខន្តិកៈសហគមន៍ ..... 74
ទម្រង់គំរូទី១៣៖ គំរូរបាយការណ៍ស្តីពីលទ្ធផល នៃអង្គប្រជុំអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈនិងជ្រើសរើសគណៈកម្មាធិការ ..... 74
ទម្រង់គំរូទី១៤៖គំរូកំណត់ហេតុអង្គប្រជុំរបស់សហគមន៍ជនជាតិដើមភាគតិច ..... 77
ទម្រង់គំរូទី១៥៖ គំរូប្រវត្តិរូបសង្ខេបរបស់សមាជិកគណៈកម្មាធិការសហគមន៍ ..... 79
ទម្រង់គំរូទី១៦៖ គំរូពាក្យសុំចុះឈ្មោះសហគមន៍ជនជាតិដើមភាគតិច ..... 81
ទម្រង់គំរូទី១៧៖ គំរូលិខិតចុះបញ្ជីទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិច ..... 84
ទម្រង់គំរូទី១៨៖ លិខិត និងសំណុំឯកសារដែលបានចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច ..... 85
ឧបសម្ព័ន្ធទី៣៖ សហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យចុះបញ្ជីសម្ធហាភាព ..... 87
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វាស់វែង ការបិទផ្សាយ អនុបយោគ ដើម្បីចេញប័ណ្ណកម្មសិទ្ធិដីសម្ធហាភាពជូនសហគមន៍ជនជាតិដើមភាគតិច ..... 87
ទម្រង់គំរូទី ១៨៖ គំរូបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ..... 88
ទម្រង់គំរូទី ១៩៖ គំរូផែនទីបឋម ..... 103
ទម្រង់គំរូទី ២០៖ គំរូពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ..... 104
ទម្រង់គំរូទី ២១៖ គំរូសេចក្តីជូនដំណឹងស្តីពីការចុះកំណត់ព្រំ ការវាស់វែង និងការវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិច ..... 105
ទម្រង់គំរូទី២២៖ បែបបទនៃការប្រមូលទិន្នន័យ ..... 106
ទម្រង់គំរូទី ២៣៖ សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិច ..... 107
ទម្រង់គំរូទី ២៤៖ លិខិតលេខ ៥៣៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីផ្ញើក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ស្តីពីការចេញវិធានការការពារបណ្តោះអាសន្ន ..... 108

ឧបសម្ព័ន្ធទី៤៖ ទម្រង់គំរូពាក់ព័ន្ធសំខាន់ៗ ........ 109
ទម្រង់គំរូទី ២៥៖ របាយការណ៍សកម្មភាព ........ 110
ទម្រង់គំរូទី ២៦៖ លិខិតប្រគល់សិទ្ធិអោយតំណាងគ្រួសារ ........ 111
ទម្រង់គំរូទី ២៧៖ លិខិតជូនដំណឹងរបស់សហាគមន៍ជនជាតិដើមភាគតិច ........ 112
ទម្រង់គំរូទី ២៨៖ សំណើរសុំប្តូសមាសភាពគណៈកម្មាធិការសហាគមន៍ជនជាតិដើមភាគតិច ........ 113
ទម្រង់គំរូទី ២៩៖ លិខិតសុំលាលែងពីមុខតំណែង ........ 114
ទម្រង់គំរូទី ៣០៖ លិខិតផ្ទេរសិទ្ធិរបស់ប្រធានសហាគមន៍ជនជាតិដើមភាគតិច ........ 115
ទម្រង់គំរូទី ៣១៖ លិខិតស្នើសុំចាកចេញពីសមាជិកភាពនៃសហាគមន៍ជនជាតិដើមភាគតិច ........ 116
ឧបសម្ព័ន្ធទី៥៖ ច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ........ 118
ច្បាប់ជាតិពាក់ព័ន្ធសិទ្ធិជនជាតិដើមភាគតិច ........ 119
គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហាគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា ........ 128
គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ........ 137
អនុក្រឹត្យលេខ៨៣ អនក្របក ស្តីពីការចុះបញ្ជីដីសហាគមន៍ជនជាតិដើមភាគតិច ........ 158
សារាចរណែនាំលេខ០៦៩ ដនស សណន របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីដែលត្រូវបានដាក់បញ្ចូលជាដីកម្មសិទ្ធិសម្ភូហភាព ឬដែលត្រូវកាត់ចេញពីដីកម្មសិទ្ធិសម្ភូហភាពរបស់សហាគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីជានីតិបុគ្គលរួច ........ 172
សារាចរណែនាំអន្តរក្រសួងលេខ ០០១ សរ / ០០៤ សរ របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីវិធានការការពារបណ្តោះអាសន្ន នូវដីដែលសហាគមន៍ជនជាតិដើមភាគតិចស្នើសុំចុះបញ្ជីដី ក្នុងពេលរង់ចាំការចុះបញ្ជីដីនោះ ជាកម្មសិទ្ធិសម្ភូហភាពរបស់សហាគមន៍ត្រូវបានបញ្ចប់តាមនីតិវិធី .. 179

# អក្សរកាត់

| | |
|---|---|
| CLT | ប័ណ្ណកម្មសិទ្ធិដីសម្ហភាព |
| CSO | អង្គការសង្គមស៊ីវិល |
| DP | ដៃគូអភិវឌ្ឍន៍ |
| EU | សហភាពអឺរ៉ុប |
| GIZ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICERD | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| ICESCR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| IP | ជនជាតិដើមភាគតិច |
| IPC | សហគមន៍ជនជាតិដើមភាគតិច |
| IPM | វិធានការការពារបណ្តោះអាសន្ន |
| LANGO | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoE | ក្រសួងបរិស្ថាន |
| MoI | ក្រសួងមហាផ្ទៃ |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NGO Forum | វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| NPDIP | គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច |
| NTFP | អនុផលព្រៃឈើ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| PDLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខេត្ត |
| PDRD | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| Sub-Decree No. 83 | អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច |
| UNDRIP | សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច |

# អារម្ភកថា

យោងតាមការចាត់ចំណាត់ក្រុមជាតិពន្ធុរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) បានឲ្យដឹងថា មានជនជាតិដើមភាគតិច (IPs) ចំនួន ២៤ ក្រុមផ្សេងៗគ្នានៅក្នុងប្រទេស។[1] ជនជាតិដើមទាំងនោះត្រូវបានប៉ាន់ស្មានថាមានចំនួន ១៧៩ ០០០ នាក់ ស្មើនឹង ១.៣៤% នៃប្រជាជនសរុប ហើយរស់នៅរាយប៉ាយតាមបណ្តាខេត្ត ចំនួន១៥ ខេត្ត និងប្រមាណជា ៤៥៥ ភូមិ។ ដូចគ្នានឹងជនជាតិដើមភាគតិចដទៃទៀតដែលរស់នៅក្នុងតំបន់ផ្សេងៗលើពិភពលោកដែរ របៀបរបបរស់នៅរបស់ជនជាតិដើមភាគតិចកម្ពុជាបានវិវដ្តអស់រយៈពេលរាប់រយឆ្នាំមកហើយ ដោយបានផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងធម្មជាតិ និងទឹកដី។ ជនជាតិដើមភាគតិចប្រកាន់ខ្ជាប់នូវវប្បធម៌ ប្រពៃណី និងជំនឿផ្សេងៗគ្នា ប៉ុន្តែពួកគេមានចំណុចរួមមួយ គឺពួកគេរស់នៅតាមបែបប្រពៃណីអាស្រ័យទាំងស្រុងទៅលើធនធានធម្មជាតិ និងដីធ្លី។ ក្នុងការទ្រទ្រង់ជីវភាពរស់នៅ ជាទូទៅ ពួកគេពឹងផ្អែកលើការដាំដំណាំដូរវេន និងការប្រមូលផលអនុផលព្រៃឈើ (NTFP) ការបរបាញ់សត្វ ការនេសាទ និងការចិញ្ចឹមសត្វ។ ដោយសារមូលហេតុនេះ ការធានាសិទ្ធិដីធ្លី គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះសមត្ថភាពរបស់ពួកគេក្នុងការថែរក្សា និងលើកកម្ពស់វប្បធម៌ពិសេសជាក់លាក់របស់ពួកគេ រួមនឹងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។ ជាមួយគ្នានេះមានកង្វល់ដ៏ធំមួយនោះគឺការបាត់បង់បន្តិចម្តងៗនូវការគ្រប់គ្រងរបស់ជនជាតិដើមភាគតិចទៅលើដីធ្លី និងធនធានធម្មជាតិនានារបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ ការលោតត្រដាងនេះឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈបរិបទមួយដែលមានការកើនឡើងនូវចំណាកស្រុក របស់ប្រជាជនដែលមិនមែនជាជនជាតិដើមភាគតិចមកក្នុងតំបន់របស់ជនជាតិដើមភាគតិច និងតាមរយៈការផ្តល់ដីសម្បទានដល់សហគ្រាសអាជីវកម្ម ដើម្បីអភិវឌ្ឍន៍ដីដែលគ្រប់គ្រងដោយសហគមន៍ជនជាតិដើមភាគតិច ហើយជារឿយៗវិធានការការពារតាមនីតិវិធីច្បាប់ត្រូវបានយកចិត្តទុកដាក់តិចតួចបំផុត និងដោយគ្មានការទូទាត់សំណងគ្រប់គ្រាន់ឡើយ។ ឱកាសមានកម្រិតរបស់ពួកគេ សម្រាប់ជះឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចចិត្តនានាដែលមានសារៈសំខាន់ចំពោះពួកគេ ហើយការបាត់បង់ដី និងមុខរបរចិញ្ចឹមជីវិតបានធ្វើឲ្យជនជាតិដើមភាគតិចក្លាយជាក្រុមមនុស្សដែលបាត់បង់ឱកាស និងងាយរងគ្រោះបំផុតនៅប្រទេសកម្ពុជា ដោយកម្រិតជីវភាពរស់នៅរបស់ពួកគេមានកម្រិតទាបជារួម។

ឆ្លើយតបទៅនឹងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវសិទ្ធិរបស់ជនជាតិដើមភាគតិចទៅលើដីធ្លីរបស់ពួកគេ ដោយអនុញ្ញាតឲ្យពួកគេចុះបញ្ជីដីសមូហភាពបាន។ នីតិកម្មនេះគឺជាវឌ្ឍនភាពបំផុតមួយនៅក្នុងចំណោមវឌ្ឍនភាពដ៏ធំបំផុតនានាដែលមាននៅក្នុងតំបន់ ហើយប្រសិនបើបានផ្តល់នូវសុពលភាពជាក់ស្តែង នោះអាចចាត់ទុកជាការអនុវត្តល្អប្រសើរបំផុតសម្រាប់ប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលកំពុងដំណើរការរៀបចំក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយរបស់ខ្លួន ស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាសមូហភាពនេះដែរ។

នីតិវិធីដែលបានដាក់ឲ្យអនុវត្តសម្រាប់ជនជាតិដើមភាគតិច ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព (CLT) មានបីដំណាក់កាលសំខាន់ៗ៖ ទីមួយ សហគមន៍ជនជាតិដើមភាគតិច (IPC) ត្រូវស្វ័យកំណត់អត្តសញ្ញាណខ្លួនជា "ជនជាតិដើមភាគតិច" រួចហើយដាក់ពាក្យទៅក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ដើម្បីសុំការទទួលស្គាល់ថាជាសហគមន៍ជនជាតិដើមភាគតិចពិតប្រាកដមែន ទីពីរ

[1] ល្អិន ស្អូច សួយ កាចក់ ថ្នូន មិល ក្រោល កាវ៉ែត លុន ខោញ ព្នង ខិ សំរ៉ៃ គ្រឹង ចារាយ ទំពូន ស្មៀង កួយ ជង កាវ៉ែត រ៉ដៃ ព័រ ព្រៅ និងស្លុង

សហគមន៍ជនជាតិដើមភាគតិចត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ (MoI) ជានីតិបុគ្គល និងទីបី សហគមន៍ជនជាតិដើមភាគតិចត្រូវដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)។ ដៃគូរអភិវឌ្ឍន៍ (DP) មានដូចជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលបានធ្វើការគាំទ្រដំណើរការសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយសហការជាមួយនឹងអាជ្ញាធររដ្ឋមានសមត្ថកិច្ច បានកត់សម្គាល់ឃើញថាដំណើរការអនុវត្ត ជារឿយៗ ប្រើប្រាស់រយៈពេលវែង ចំណាយច្រើន និងស្មុគស្មាញ ហើយពេលខ្លះមានភាពមិនស៊ីសង្វាក់គ្នារវាងបណ្តាខេត្ត និងអាជ្ញាធរទាំងនោះទៀតផង។

ពេលរៀបចំពង្រាងសៀវភៅមគ្គុទេសក៍នេះ ក្នុងឆ្នាំ២០១៨ មានសហគមន៍ជនជាតិដើមភាគតិចចំនួន ១៤១ សហគមន៍ត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ (ដំណាក់កាលទី១) ជាជនជាតិដើមភាគតិច និងសហគមន៍ចំនួន ១២៨ ត្រូវបានទទួលស្គាល់ជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ (ដំណាក់កាលទី២) និងមានសហគមន៍ចំនួន ២៤ ដែលបានបំពេញដំណើរការទាំងស្រុង ហើយទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព (ដំណាក់កាលទី៣)។

ដើម្បីសម្របសម្រួលដល់ដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ គេត្រូវតែទទួលស្គាល់ថា វាមានតម្រូវការប្រមូលយកព័ត៌មានចាំបាច់ទាំងអស់ ស្តីពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរួចចងក្រងជាសំណុំឯកសារមួយ ដើម្បីផ្តល់ជាការណែនាំ និងដើម្បីធ្វើឲ្យមានសុខដុមនីយកម្មដំណើរការទាំងនោះ។ ឆ្លើយតបនឹងមូលហេតុនេះ អ្នកនិពន្ធសៀវភៅណែនាំនេះបានសិក្សាច្បាប់ជាតិពាក់ព័ន្ធទាំងអស់ គោលនយោបាយ សារាចរនានា ហើយនិងឯកសារផ្សព្វផ្សាយដែលចេញដោយដៃគូរអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល (CSO)។ ក្រៅពីនេះ ដោយហេតុថាជំហានមួយចំនួននៅក្នុងចំណោមជំហានទាំងអស់ និងសកម្មភាពនានា នៅក្នុងដំណើរការសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពត្រូវបានរៀបចំ និងបង្កើតឡើងតាមរយៈការអនុវត្ត (ជាក់ស្តែង) ដូច្នេះការសម្ភាសក៏ត្រូវបានធ្វើឡើងជាមួយនឹងក្រសួងពាក់ព័ន្ធផងដែរ ដើម្បីប្រមូលយកព័ត៌មានអំពីដំណើរការស្នើសុំទាំងនោះ។

សៀវភៅណែនាំនេះបានលើកយកមកបង្ហាញនូវជំហាន និងសកម្មភាពចាំបាច់ទាំងអស់តាមលំដាប់លំដោយ និងលម្អិតសម្រាប់បំពេញនៅក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ក្នុងគោលបំណងធ្វើឲ្យសៀវភៅមគ្គុទេសក៍នេះអាចផ្តល់ជាចំណេះដឹង និងការយល់ដឹងពេញលេញអំពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពទាំងមូល និងដើម្បីចាត់ទុកវាជាឧបករណ៍សម្រាប់អនុវត្តជាក់ស្តែងចំពោះអ្នកទាំងឡាយណាដែលពាក់ព័ន្ធនៅក្នុងដំណើរការ សុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយសៀវភៅនេះបានរៀបរាប់យ៉ាងលម្អិតនូវការទទួលខុសត្រូវនីមួយៗ នៅក្នុងជំហាននីមួយៗ សម្រាប់តួអង្គនីមួយៗ។

សៀវភៅនេះត្រូវបានរៀបចំឡើងដោយការិយាល័យ OHCHR ដោយមានការពិភាក្សាពិគ្រោះយោបល់ជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងមហាផ្ទៃ (MoI) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក្រសួងបរិស្ថាន (MoE) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងអង្គការសង្គមស៊ីវិលមួយចំនួនទៀត។ សូមថ្លែងអំណរគុណជាពិសេសចំពោះបណ្តាក្រសួងទាំងនោះសម្រាប់ការផ្តល់ព័ត៌មានផ្លូវការពាក់ព័ន្ធ នឹងទម្រង់លិខិតនានា។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណចំពោះបុគ្គលិករបស់អង្គការសង្គមស៊ីវិលទាំងអស់ ដែលបានផ្តល់ជាមតិយោបល់ដ៏មានតម្លៃ ដោយផ្អែកលើបទពិសោធន៍ដ៏ច្រើនរបស់ពួកគេ។

# មូលដ្ឋានច្បាប់

នៅថ្នាក់អន្តរជាតិ សន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនដែលកម្ពុជាជាភាគីមួយដែរនោះ មានដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) និងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) បានគូសបញ្ជាក់អំពីសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការអភិវឌ្ឍដោយសេរីទៅលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ពួកគេ។ ក្រៅពីនេះ សិទ្ធិរបស់ជនជាតិដើមភាគតិចក៏ត្រូវបានកំណត់ និងបញ្ជាក់បន្ថែមដោយសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (UNDRIP) ដែលកម្ពុជាបានបោះឆ្នោតគាំទ្រកាលពីខែកញ្ញា ឆ្នាំ២០០៧ ផងដែរ។ សិទ្ធិដែលមានចែងនៅក្នុងសេចក្តីប្រកាស UNDRIP មានបំណងការពារនូវសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច បន្ថែមលើសិទ្ធិបុគ្គលរបស់ពួកគេម្នាក់ៗ ពីព្រោះការទទួលស្គាល់នូវសិទ្ធិទាំងនោះគឺជាការចាំបាច់ណាស់ដើម្បីធានានូវការបន្តអត្ថិភាព ការអភិវឌ្ឍ និងសុខុមាលភាពរបស់ជនជាតិដើមភាគតិច ជាជនជាតិមួយដែលមានលក្ខណៈផ្ទាល់របស់ខ្លួន។ សេចក្តីប្រកាស UNDRIP មាត្រា ២៦.៣ បានតម្រូវឲ្យរដ្ឋផ្តល់នូវការទទួលស្គាល់តាមផ្លូវច្បាប់ និងការការពារទៅលើដីធ្លី ដែនដី និងធនធានធម្មជាតិនានារបស់ជនជាតិដើមភាគតិច។ ការងារនេះ មានដូចជាការកំណត់អត្តសញ្ញាណ (ដីធ្លី) ការកំណត់ព្រំប្រទល់ ការផ្តល់ប័ណ្ណកម្មសិទ្ធិ និងការទទួលស្គាល់តាមផ្លូវច្បាប់ផ្សេងៗទៀតទៅលើដីធ្លីរបស់ពួកគេ។ ជាមួយគ្នានេះដែរ មាត្រា១០ បានចែងថា "ជនជាតិដើមភាគតិចនឹងមិនត្រូវបានបណ្តេញចេញដោយបង្ខំពីដី ឬដែនដីរបស់ពួកគេឡើយ" ហើយមាត្រា២៦.១ ក៏បានចែងថា "ជនជាតិដើមភាគតិចមានសិទ្ធិទៅលើដីធ្លី ដែនដី និងធនធានធម្មជាតិនានា ដែលពួកគេគឺជាម្ចាស់តាមបែបប្រពៃណី ឬកាន់កាប់ ឬប្រើប្រាស់ ឬទទួលបាន តាមបែបផ្សេងពីនេះ។"

នៅក្នុងកម្រិតថ្នាក់ជាតិ មាត្រា៤៤ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានចែងថា "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី"។ ច្បាប់ភូមិបាលឆ្នាំ ២០០១ ក៏បានបញ្ញត្តិបន្ថែមទៀតអំពីកម្មសិទ្ធិដីធ្លីនៅក្នុងប្រទេសកម្ពុជា និងបានបែងចែកចំណាត់ថ្នាក់ដីសំខាន់ៗ ចំនួនបីប្រភេទ៖ * "ដីឯកជន" គឺជាដីដែលមានសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដោយស្របច្បាប់ ជាលក្ខណៈបុគ្គល ឬរួមគ្នាដោយបុគ្គល ឬក្រុមហ៊ុន។ * "ដីសាធារណៈរបស់រដ្ឋ" គឺជាដីដែលរក្សាតម្លៃខាងប្រយោជន៍ជាសាធារណៈរបស់ដី ដីប្រភេទនេះត្រូវបានកាន់កាប់កម្មសិទ្ធិដោយរដ្ឋ និងត្រូវបានរឹតត្បិត និងមិនអាចត្រូវបានផ្តល់ក្នុងទម្រង់ជាសម្បទានដីសេដ្ឋកិច្ចបានឡើយ។ * "ដីឯកជនរបស់រដ្ឋ" គឺជាដីដែលមិនមែនជាដីឯកជន ឬរក្សាតម្លៃខាងប្រយោជន៍ជាសាធារណៈរបស់ដីទៀតឡើយ គឺជាដីឯកជនរបស់រដ្ឋតាមអង្គហេតុ។ ដីនេះគឺជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែអាចលក់ ជួល និងផ្តល់ជាសម្បទានដីបាន។ ច្បាប់ភូមិបាលឆ្នាំ ២០០១ (ជំពូក ៣ ផ្នែកទី២) ក៏បានធានានូវសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការទទួលបាននូវ "កម្មសិទ្ធិសមូហភាព" ទៅលើដីធ្លីរបស់ពួកគេ ដែលពួកគេបានតាំងលំនៅ និងប្រកបរបរកសិកម្មតាមប្រពៃណីផងដែរ។ អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (អនុក្រឹត្យលេខ ៨៣) បានចែងអំពីនីតិវិធីសម្រាប់ជនជាតិដើមភាគតិចចុះបញ្ជី"កម្មសិទ្ធិសមូហភាព" នោះនៅក្នុងទម្រង់ជាប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ទោះបីជា "កម្មសិទ្ធិសមូហភាព" មានចែងអំពីសិទ្ធិជាច្រើននៅក្នុងចំណោមសិទ្ធិនានា និងការការពារកម្មសិទ្ធិ ដែលទទួលបានដោយកម្ម

សិទ្ធិករដីឯកជនក៏ដោយ ក៏ជាការសំខាន់ត្រូវយល់ថាប័ណ្ណកម្មសិទ្ធិដីសមូហភាពនឹងត្រូវចុះបញ្ជីនៅលើដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ហើយនិងបន្តកម្មសិទ្ធិដោយរដ្ឋ។[2] ដូច្នេះ សហគមន៍ជនជាតិដើមភាគតិចនឹងមិនត្រូវបានផ្តល់សិទ្ធិឲ្យលក់ ឬផ្ទេរដីសមូហភាពនេះទៅឲ្យជនណាមួយក្រៅពីសហគមន៍ជនជាតិដើមភាគតិចបានឡើយ។ យ៉ាងនេះក្តី ការណ៍នេះអាចបម្រើឲ្យការការពារចំពោះដីរបស់ជនជាតិដើមភាគតិចបាន។

បន្ថែមពីលើនេះ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (NPDIP) ក៏បានធានានូវសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិ ប្រើប្រាស់ និងគ្រប់គ្រងនូវដីសហគមន៍របស់ពួកគេតាមបែបសមូហភាព។ គោលនយោបាយនេះក៏បានដាក់បញ្ចូលនូវសិទ្ធិក្នុងការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍដីសហគមន៍ និងសិទ្ធិមិនលក់ដីសហគមន៍របស់ពួកគេ ឬបណ្តេញចេញដោយបង្ខំពីដីរបស់ពួកគេ។ សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចេញនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៩ ដែលបានផ្តល់នូវការណែនាំអំពីការអនុវត្ត NPDIP បានទទួលស្គាល់ថាមុខរបររបស់ជនជាតិដើមភាគតិចមានការផ្សារភ្ជាប់គ្នាទៅនឹងធនធានធម្មជាតិ និងបានចែងទៀតថាជនជាតិដើមភាគតិចមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ និងប្រើប្រាស់ដី។

ច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិទាំងនេះបានបង្កើតឡើងនូវមូលដ្ឋានគ្រឹះនៃដំណើរការសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព និងគឺជាមូលដ្ឋានរបស់សៀវភៅមគ្គុទេសក៍នេះ។ ជាមួយគ្នានេះដែរ ជំហានមួយចំនួននៅក្នុងចំណោមបណ្តាជំហានលម្អិតទាំងអស់ និងសកម្មភាពនៅក្នុងកិច្ចដំណើរការសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព មិនមានចែងលម្អិតនៅក្នុងច្បាប់ ឬបទប្បញ្ញត្តិ ឬគោលនយោបាយណាមួយឡើយ ប៉ុន្តែវាត្រូវបានរៀបចំឡើងផ្អែកតាមការអនុវត្ត (ជាក់ស្តែង) ប៉ុណ្ណោះ។ **ដូច្នេះហើយ ជំហាន ឬសកម្មភាពដែលមាននៅក្នុងសៀវភៅណែនាំនេះ គឺផ្អែកលើការអនុវត្តដែលបានធ្វើមកតែប៉ុណ្ណោះ ដោយមិនអាចយោងជាច្បាប់បានឡើយ។**

---

[2] មាត្រា ៦ "ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មានដីឯកជនរបស់រដ្ឋ ដូចជា ៖

- ដីលំនៅឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
- ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី មានដីដាំដុះជាក់ស្តែង ដីស្រែចម្ការ
- ដីសាធារណៈរបស់រដ្ឋ ដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋ ដូចជា ៖
- ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងមានការព្រមព្រៀងពីអ្នកជិតខាង
- ដីព្រៃអារក្ស ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី ប្រាំពីរ (០៧) ហិកតា
- ដីកប់ខ្មោច ដែលអាចមានមួយកន្លែង ឬច្រើនកន្លែង សម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពីប្រាំពីរ (០៧) ហិកតា។"

# ដំណើរការនៃនីតិវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច



# ដំណាក់កាលទី១៖

## ក្រសួងអភិវឌ្ឍន៍ជនបទ៖ ការកំណត់អត្តសញ្ញាណ សហគមន៍ជនជាតិដើមភាគតិច

# សេចក្តីផ្តើម

ដោយហេតុថាច្បាប់ភូមិបាលឆ្នាំ ២០០១ ផ្តល់នូវការទទួលស្គាល់ទាំងស្រុងនូវដីសមូហភាពសម្រាប់ជនជាតិដើមភាគតិច ដូច្នេះដំណាក់កាលដំបូងនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺសហគមន៍ត្រូវស្វ័យកំណត់អត្តសញ្ញាណខ្លួនជា "សហគមន៍ជនជាតិដើមភាគតិច" ហើយបន្ទាប់មកក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវផ្តល់សុពលភាព និងទទួលសស្គាល់អត្តសញ្ញាណសហគមន៍ថាជាសហគមន៍ជនជាតិដើមភាគតិច។

**សកម្មភាពតម្រូវឲ្យអនុវត្តនៅក្នុងដំណាក់កាលទី១ ៖**
**<u>ជំហានទី១៖</u>** ធ្វើការផ្សព្វផ្សាយការយល់ដឹងនៅក្នុងចំណោមអាជ្ញាធរថ្នាក់ខេត្ត (មន្ទីរជំនាញពាក់ព័ន្ធ) ស្រុក ឃុំ ភូមិ និងសហគមន៍ជនជាតិដើមភាគតិច
**<u>ជំហានទី២៖</u>** សហគមន៍ជនជាតិដើមភាគតិច បង្ហាញឆន្ទៈក្នុងការចាប់ផ្តើមដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច
**<u>ជំហានទី៣៖</u>** ធ្វើការផ្សព្វផ្សាយដល់សហគមន៍គោលដៅ
**<u>ជំហានទី៤៖</u>** សហគមន៍ជនជាតិដើមភាគតិច ត្រូវបោះឆ្នោតជ្រើសរើសតំណាងគណៈកម្មាធិការសហគមន៍ និងប្រកាសស្វ័យអត្តសញ្ញាណខ្លួនជា "ជនជាតិដើមភាគតិច"
**<u>ជំហានទី៥៖</u>** ការដាក់ពាក្យ ការវាយតម្លៃ និងទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចរបស់សហគមន៍ជនជាតិដើមភាគតិច
<u>ក្រសួងអភិវឌ្ឍន៍ជនបទចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច។</u>

## ជំហានទី ១៖ ធ្វើការផ្សព្វផ្សាយការយល់ដឹងនៅក្នុងចំណោមអាជ្ញាធរថ្នាក់ខេត្ត (មន្ទីរជំនាញពាក់ព័ន្ធ) ស្រុក ឃុំ ភូមិ និងសហគមន៍ជនជាតដើមភាគតច

ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទ (PDRD) មានភារៈកិច្ចនៅក្នុងការផ្សព្វផ្សាយការយល់ដឹងអំពីខ្លឹមសារនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងសារាចរណែនាំនានាពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជានីតិវិធីនៃការចុះបញ្ជីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច អាជ្ញាធរមូលដ្ឋាន នៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ថ្នាក់ភូមិ។ នៅក្នុងការអនុវត្តការងារនេះ មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទនឹងរៀបចំផ្សព្វផ្សាយព័ត៌មានមួយ ដែលនៅក្នុងនោះពួកគេនឹងផ្តល់នូវព័ត៌មានអំពីសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនានា ក៏ដូចជាសកម្មភាពដែលនឹងត្រូវអនុវត្តនៅក្នុងតំបន់របស់ពួកគេ។ អាជ្ញាធរមូលដ្ឋានខាងក្រោមទាំងនេះនឹងត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងការផ្សព្វផ្សាយព័ត៌មាន៖ មន្ទីរវប្បធម៌ និងវិចិត្តសិល្បៈ មន្ទីររៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មន្ទីរ

ទេសចរណ៍ សាលាខេត្ត (អង្គភាពរដ្ឋបាល និងទីចាត់ការអន្តរៈវិស័យ) អាជ្ញាធរថ្នាក់ស្រុកពាក់ព័ន្ធទាំងអស់ និងលោកមេឃុំទាំងអស់។[3]

## ជំហានទី២៖ សហគមន៍ជនជាតិដើមភាគតិចបង្ហាញឆន្ទៈក្នុងការចាប់ផ្តើមដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច

សហគមន៍ជនជាតិដើមភាគតិចទាំងឡាយណា ដែលចាប់អារម្មណ៍ទៅលើការកំណត់អត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិច តាមរយៈកិច្ចប្រជុំផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច អាចចាប់ផ្តើមដំណើរការដាក់ពាក្យសុំធ្វើការកំណត់អត្តសញ្ញាណបាន ដោយពិភាក្សាអំពីការងារនេះជាមួយនឹងមន្ទីរ/ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងចុះពិនិត្យសិក្សាដើម្បីកំណត់អត្តសញ្ញាណសហគមន៍គោលដៅទាំងនោះ ដោយសហការជាមួយនឹងក្រសួងពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល។[4] បន្ទាប់ពីការព្រមព្រៀងគ្នា នោះក្រសួងអភិវឌ្ឍន៍ជនបទនឹងផ្ញើលិខិតមួយច្បាប់ (ទម្រង់លិខិតលេខ ១) ទៅអភិបាលខេត្តពាក់ព័ន្ធ ដោយជូនដំណឹងដល់រូបគាត់ថា ដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនឹងត្រូវធ្វើឡើងនៅក្នុងតំបន់ជាក់លាក់ណាមួយហើយ ដោយទាំងបញ្ជាក់ប្រាប់អំពីបេសកកម្ម និងសកម្មភាពដែលត្រូវអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូរបស់ក្រសួង រួចហើយស្នើសុំកិច្ចសហប្រតិបត្តិការពីអាជ្ញាធរនានា។ បន្ទាប់មក លោកអភិបាលខេត្តនឹងផ្ញើលិខិតមួយច្បាប់ (ដោយភ្ជាប់ជាមួយនូវលិខិតរបស់ក្រសួងអភិវឌ្ឍន៍ជនបទផង) ទៅឲ្យអាជ្ញាធរថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការពីពួកគេ។

## ជំហានទី៣ ៖ ធ្វើការផ្សព្វផ្សាយដល់សហគមន៍គោលដៅ

ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទ ក៏ទទួលខុសត្រូវផងដែរទៅលើកាផ្សព្វផ្សាយការយល់ដឹងនៅក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចអំពី ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ដោយហេតុថាមានតែសហគមន៍ "ជនជាតិដើមភាគតិច" ប៉ុណ្ណោះមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ ហើយអត្តសញ្ញាណជា "ជនជាតិដើមភាគតិច" របស់សហគមន៍ត្រូវមានការបញ្ជាក់ច្បាស់លាស់។[5] ជាដំបូង សហគមន៍ជនជាតិដើមភាគតិចត្រូវធ្វើស្វ័យកំណត់អត្តសញ្ញាណខ្លួនថាពិតជាជនជាតិដើមពិតប្រាកដមែន។ ដើម្បីជួយពួកគេនៅក្នុងការធ្វើការងារនេះ ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទនឹងរៀបចំនូវកិច្ចប្រជុំមួយ ជាមួយនឹងសហគមន៍ដើម្បីជូនដំណឹងពួកគេអំពីដំណើរការ និងដើម្បីផ្តល់នូវពេលវេលាដល់សមាជិកសហគមន៍ម្នាក់ៗក្នុង

[3] សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំណុច ក.១

[4] សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំណុច គ.៥ (ក)

[5] សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំណុច ខ.២

ការសម្រេចថាតើពួកគេចង់ក្លាយជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែរ ឬក៏អត់ និងចង់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពដែរ ឬទេ។ សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកតំណាងអភិបាលស្រុកតម្រូវឲ្យចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល ក៏ត្រូវបានលើកទឹកចិត្តឲ្យគាំទ្រដំណើរការនៃការផ្សព្វផ្សាយការយល់ដឹងនៅក្នុងសហគមន៍ជនជាតិដើមភាគតិចនេះដែរ។ [6]

**ព័ត៌មានខាងក្រោមត្រូវលើកយកមកបង្ហាញនៅក្នុងកិច្ចប្រជុំ[7]៖**

ក) ក្របខ័ណ្ឌច្បាប់៖

- ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា៨ ១០ និង ២៥-២៨
- ច្បាប់ស្តីពីព្រៃឈើ មាត្រា៣៧ និង ៤០-៤៥
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (NPDIP)
- អនុក្រឹត្យលេខ ៨៣ អនក្រ បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៩
- សារាចរផ្សេងៗទៀត (ជាពិសេសទម្រង់លិខិតដែលតម្រូវឲ្យមានសម្រាប់ការដាក់ពាក្យស្នើសុំបញ្ជាក់អត្តសញ្ញាណជាជនជាតិដើមភាគតិចទៅក្រសួងអភិវឌ្ឍន៍ជនបទ)

ខ) ដំណើរការដែលមានបីដំណាក់កាលសម្រាប់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។

**ចំណុចខាងក្រោមត្រូវធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំ៖**

ក) តើនរណាខ្លះនៅក្នុងសហគមន៍ដែលចង់ចុះឈ្មោះជាសមាជិកសហគមន៍ជនជាតិដើមភាគតិច ហើយក្លាយជាអ្នកស្នើសុំកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីជានីតិបុគ្គល និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព

ខ) ព្រំដីនៃដីសហគមន៍ដែលធ្វើការទាមទារ (ស្នើសុំ)

ភូមិមួយចំនួនមានទាំងជនជាតិដើមភាគតិច និងជនជាតិខ្មែររស់នៅលាយឡំគ្នា។ នៅក្នុងភូមិដែលមានស្ថានភាពបែបនេះ នោះមានតែបុគ្គលដែលជាជនជាតិដើមភាគតិចប៉ុណ្ណោះ ទើបអាចចុះឈ្មោះជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចបាន។ យ៉ាងនេះក្តី គូភរិយាស្វាមី ដែលក្នុងនោះមានភាគីណាមួយជាជនជាតិដើមភាគតិច និងភាគីម្ខាងទៀតជាជនជាតិខ្មែរ មានសិទ្ធិចុះឈ្មោះបាន។ ក្នុងករណីជនជាតិខ្មែរដែលរស់នៅក្នុងសហគមន៍ជនជាតិដើមភាគតិច មានបំណងគោរពប្រតិបត្តិតាមប្រពៃណី ទំនៀមទម្លាប់ជនជាតិដើមភាគតិច អាចមានសិទ្ធិសុំចូលជាសមាជិកសហគមន៍បានប្រសិនបើមានការទទួលស្គាល់ដោយសហគមន៍ទាំងមូល។ ជនជាតិដើមភាគតិចក៏អាចសម្រេចចិត្តមិនចូលរួមជាមួយនឹងសហគមន៍ជនជាតិដើមភាគតិចបានដែរ។

អ្នកសម្របសម្រួលមកពីក្រសួងអភិវឌ្ឍន៍ជនបទ/មន្ទីរអភិវឌ្ឍន៍ជនបទ ត្រូវធានាថាសមាជិកសហគមន៍មានការយល់ដឹងពេញលេញអំពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ក៏

[6] សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំណុច ក.៥

[7] សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ សេចក្តីផ្តើម

ដូចជាលើកទឹកចិត្តឲ្យមានការពិភាក្សាជាចំហ ដោយបង្កបរិយាកាសឲ្យសមាជិកសហគមន៍អាចលើកឡើងនូវសំណួរសំខាន់ៗ និងកង្វល់របស់ពួកគេបានដោយសេរី។ ចុងក្រោយនេះ ពួកគេក៏ត្រូវធ្វើការវាយតម្លៃដែរថាតើសមាជិកសហគមន៍ពិតជាមានសុឆន្ទៈប្រាកដដែរ ឬក៏អត់នៅក្នុងការបំពេញដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូភាព។ កំណត់ហេតុកិច្ចប្រជុំគួរត្រូវបានរៀបចំឲ្យមាន រួចហើយត្រូវកត់ត្រាចូលនូវរាល់ការធ្វើសេចក្តីសម្រេចចិត្តទាំងអស់។

## ជំហានទី៤ ៖ សហគមន៍ជនជាតដើមភាគតិចបោះឆ្នោតជ្រើសរើសតំណាងគណៈកម្មាធិការសហគមន៍ និងស្វ័យអត្តសញ្ញាណខ្លួនជា "ជនជាតដើមភាគតិច"

នៅពេលដែលដំណើរការនៃការកំណត់ ថាតើបុគ្គលមួយណានឹងក្លាយជាសមាជិកសហគមន៍ជនជាតិដើមភាគតិចត្រូវបានបញ្ចប់ នោះមន្ទីរអភិវឌ្ឍន៍ជនបទដោយសហការជិតស្និទជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ ត្រូវរៀបចំនូវកិច្ចប្រជុំមួយដែលសហគមន៍នឹងធ្វើស្វ័យកំណត់អត្តសញ្ញាណជា "ជនជាតិដើមភាគតិច" និងត្រូវបានទទួលស្គាល់ថាជាសហគមន៍ជនជាតិដើមភាគតិច ដោយសហគមន៍ជិតខាង និងអាជ្ញាធរមូលដ្ឋាន។ សហគមន៍ក៏ត្រូវបោះឆ្នោតជ្រើសរើសតំណាងគណៈកម្មាធិការសហគមន៍របស់ខ្លួនផងដែរ នៅក្នុងកិច្ចប្រជុំដដែលនោះ ដែលនឹងត្រូវតំណាងឲ្យសហគមន៍នៅក្នុងដំណើរការនៃការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។[8] តំណាង គណៈកម្មាធិការសហគមន៍ ក៏ទទួលខុសត្រូវចំពោះការពិនិត្យមើលថាតើអនាគត បទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រងដីធ្លី និងយន្តការដោះស្រាយវិវាទ ត្រូវបានគោរព និងអនុវត្តដោយសមាជិកសហគមន៍ជនជាតិដើមភាគតិចដែរ ឬក៏អត់។

យោងតាមការអនុវត្តកន្លងមក គោលការណ៍ណែនាំស្តីពីនីតិវិធីខាងក្រោមគួរត្រូវបានគោរពសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងគណៈកម្មាធិការសហគមន៍៖ សមាជិកសហគមន៍ជនជាតិដើមភាគតិច (ទាំងស្ត្រី និងបុរស) ត្រូវស្ម័គ្រចិត្តឈរឈ្មោះជាបេក្ខជន/បេក្ខនារី។ បេក្ខជន/បេក្ខនារីទាំងអស់នៅក្នុងការបោះឆ្នោតនេះតម្រូវឲ្យបញ្ជាក់ប្រាប់អំពីគោលបំណងរបស់ខ្លួនក្នុងការការពារ និងអភិវឌ្ឍន៍សហគមន៍ពួកគេ។ សមាជិកសហគមន៍ជនជាតិដើមភាគតិចទាំងអស់ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំមួយ ដែលពួកគេត្រូវបោះឆ្នោតឲ្យបេក្ខជន/បេក្ខនារីជាទីពេញចិត្តរបស់ពួកគេ។ ការបោះឆ្នោតត្រូវធ្វើឡើងដោយសេរី គ្មានការបង្ខិតបង្ខំ ឬការបំភិតបំភ័យណាមួយឡើយ។ ចំនួនសមាជិកតំណាងគណៈកម្មាធិការអាចមានចំនួនខុសៗគ្នា ពីសហគមន៍ជនជាតិដើមភាគតិចមួយទៅសហគមន៍ជនជាតិដើមមួយទៀត អាស្រ័យទៅលើទំហំនៃសហគមន៍ជនជាតិដើមភាគតិចដែលលើកមកពិភាក្សាទាំងនោះ ប៉ុន្តែជាទូទៅចំនួនសមាជិកតំណាងគណៈកម្មាធិការគួរមានចំនួនចន្លោះពីប្រាំពីរនាក់ដល់ដប់មួយនាក់។ ចំនួនសមាជិកគណៈកម្មាធិការត្រូវមានចំនួនសេស ដើម្បីឲ្យមានសំឡេងឆ្នោតភាគច្រើន។ [9] បេក្ខជន/បេក្ខនារីដែលបានទទួលសំឡេងឆ្នោតច្រើនជាងគេបំផុតនឹងក្លាយជា

[8] សារាចរលេខ ៩៧៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំណុច ខ.២

[9] ស្ត្រីគួរត្រូវបានលើកទឹកចិត្តជាពិសេសឲ្យចូលរួមជាបេក្ខជនឈរឈ្មោះបោះឆ្នោត។ ការិយាល័យ OHCHR សូមលើកទឹកចិត្តដល់បណ្តាសហគមន៍ជនជាតិដើមភាគតិចទាំងអស់ ឲ្យខិតខំប្រឹងប្រែងធ្វើឲ្យគណៈកម្មាធិការសហគមន៍ខ្លួនមានការចូលរួមពីសំណាក់ស្ត្រី និងបុរសនៅក្នុងចំនួនប្រហាក់ប្រហែលគ្នាបំផុត។

ប្រធានគណៈកម្មាធិការសហគមន៍ ហើយអ្នកដែលបានសំឡេងបន្ទាប់នឹងក្លាយជាអនុប្រធាន។ អ្នកដែលទទួលបានសំឡេងច្រើនជាងគេលំដាប់ទីបី ជាទូទៅក្លាយជាលេខាធិការ ឬមន្ត្រីរដ្ឋបាលហិរញ្ញវត្ថុ អាស្រ័យលើការសម្រេចនៅក្នុងកិច្ចប្រជុំ។ បេក្ខជន/បេក្ខនារីជាប់ឆ្នោតដែលនៅសេសសល់ក្លាយជាសមាជិកសាមញ្ញនៃគណៈកម្មាធិការ។

ក្នុងកិច្ចប្រជុំដដែលនោះ សហគមន៍ត្រូវធ្វើស្វ័យកំណត់អត្តសញ្ញាណជាផ្លូវការជាសហគមន៍ "ជនជាតិដើមភាគតិច"។ នេះមានន័យថាសមាជិកសហគមន៍ត្រូវប្រកាសខ្លួនពួកគេជាជនជាតិដើមភាគតិច ដោយផ្អែកលើវប្បធម៌ ជំនឿ ភាសា និង/ឬប្រពៃណី និងទំនៀមទម្លាប់ពួកគេ។ ការណ៍នេះគួរធ្វើឡើងតាមរយៈការប្រកាសដោយផ្ទាល់មាត់ ដែលនឹងត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុកិច្ចប្រជុំ។ ក្រៅពីនេះ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរមួយទៀតអំពីស្វ័យកំណត់អត្តសញ្ញាណជា "ជនជាតិដើមភាគតិច" នេះក៏គួររៀបចំឡើងដោយសហគមន៍ផងដែរ (ទម្រង់លិខិតលេខ ៣)។

សមាជិកគណៈកម្មាធិការសហគមន៍ដែលបានជាប់ឆ្នោត ត្រូវរៀបចំកំណត់ហេតុកិច្ចប្រជុំការបោះឆ្នោតនេះ ដោយដាក់បញ្ចូលបញ្ជីរាយនាមបេក្ខជន/បេក្ខនារីទាំងអស់ដែលឈរឈ្មោះបោះឆ្នោត បញ្ជីរាយនាមអ្នកតំណាងដែលបានជាប់ឆ្នោត និងបញ្ជីរាយនាមអ្នកចូលរួមនៅក្នុងការបោះឆ្នោត (ទម្រង់លិខិតលេខ ២)។ កំណត់ត្រានេះគួរត្រូវបានចុះហត្ថលេខាដោយអ្នកកត់ត្រា (ជាទូទៅ គឺមន្ទីរអភិវឌ្ឍន៍ជនបទ) និងបញ្ជាក់ដោយប្រធានអង្គប្រជុំ (ជាទូទៅ មេឃុំ ឬអភិបាលស្រុក)។

ប្រធានភូមិ និងអ្នកតំណាងមកពីក្រុមប្រឹក្សាឃុំ និងសាលាស្រុក ត្រូវសង្កេតការណ៍នៅក្នុងការបោះឆ្នោត និងធានាថាការបោះឆ្នោតនេះធ្វើឡើងដោយយុត្តិធម៌ សេរី និងតម្លាភាព។ ដៃគូអភិវឌ្ឍន៍ អង្គការ សង្គមស៊ីវិលគួរត្រូវបានអញ្ជើញដោយអ្នករៀបចំក្នុងឋានៈជាអ្នកសង្កេតការណ៍។

## ជំហានទី៥ ៖ ការដាក់ពាក្យ ការវាយតម្លៃ និងទទួលស្គាល់អត្តសញ្ញាណសហគមន៍ ជនជាតិដើមភាគតិចរបស់សហគមន៍ជនជាតិដើមភាគតិច

### ការដាក់ពាក្យស្នើសុំរបស់សហគមន៍ជនជាតិដើមភាគតិច

បន្ទាប់ពីសមាជិកសហគមន៍បានធ្វើស្វ័យកំណត់អត្តសញ្ញាណខ្លួនជា "ជនជាតិដើមភាគតិច" និងបានបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហគមន៍ពួកគេរួចហើយ នោះគណៈកម្មាធិការគួរដាក់ពាក្យស្នើសុំការទទួលស្គាល់សហគមន៍ជា "ជនជាតិដើមភាគតិច" នៅក្រសួងអភិវឌ្ឍន៍ជនបទ។ មន្ទីរអភិវឌ្ឍន៍ជនបទ គួរគាំទ្រគណៈកម្មាធិការសហគមន៍នៅក្នុងការបំពេញឲ្យបានត្រឹមត្រូវនូវទម្រង់លិខិតចាំបាច់នានាសម្រាប់ការដាក់ពាក្យស្នើសុំនេះ។

ឯកសារខាងក្រោមត្រូវភ្ជាប់ជាមួយនឹងពាក្យស្នើសុំ៖

- ទម្រង់លិខិតលេខ ២៖ កំណត់ត្រាកិច្ចប្រជុំនៃការធ្វើស្វ័យកំណត់អត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិច និងការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហគមន៍ និងបញ្ជីរាយនាមអ្នកចូលរួម

- ទម្រង់លិខិតលេខ ៣៖ ការប្រកាសអំពីការធ្វើស្វ័យកំណត់អត្តសញ្ញាណខ្លួនជា "ជនជាតិដើមភាគតិច" ដោយសហគមន៍
- ទម្រង់លិខិតលេខ ៤៖ ពាក្យស្នើសុំសម្រាប់គ្រួសារនីមួយៗដើម្បីស្នើសុំចូលជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច ហើយនិងបញ្ជីរាយនាមនៃសមាជិកគ្រួសារទាំងអស់
- ទម្រង់លិខិតលេខ ៥៖ បញ្ជីរាយនាមសមាជិកសហគមន៍ទាំងអស់ ដែលចង់ក្លាយជាចំណែក (សមាជិក) មួយនៃសហគមន៍ជនជាតិដើមភាគតិច (អាយុ ១៨ ឆ្នាំ និងលើសពីនេះ) ជាមួយនិងស្នាមមេដៃ
- ទម្រង់លិខិតលេខ ៦៖ ពាក្យស្នើសុំទៅក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីស្នើសុំការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច។

ពាក្យស្នើសុំការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ត្រូវដាក់ជូនមន្ត្រីតាមលំដាប់លំដោយដូចខាងក្រោមនេះ ដើម្បីសុំហត្ថលេខាបញ្ជាក់ទៅលើអត្តសញ្ញាណ៖

១) មេឃុំ

២) អភិបាលស្រុក

៣) ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ

៤) អភិបាលខេត្ត (ដាក់ជូននូវពាក្យស្នើសុំស្ពាពរ រួមមានទាំងលិខិតអមផង សូមមើលទម្រង់លិខិតលេខ ៧)

៥) ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## ក្រសួងអភិវឌ្ឍន៍ជនបទទទួលស្គាល់សហគមន៍ជា "ជនជាតិដើមភាគតិច"

ក្រោយពីទទួលបាននូវពាក្យស្នើសុំរួចហើយ នោះអ្នកតំណាងថ្នាក់កណ្តាលមកពីក្រសួងអភិវឌ្ឍន៍ជនបទនឹងដឹកនាំបេសកកម្មចុះទៅសហគមន៍ ដើម្បីធ្វើការសម្ភាសសមាជិកសហគមន៍ និងសហគមន៍ជិតខាង ដើម្បីវាយតម្លៃ និងផ្តល់សុពលភាពទៅលើអត្តសញ្ញាណជា "ជនជាតិដើមភាគតិច" របស់សហគមន៍។ អាជ្ញាធរមូលដ្ឋាន (យ៉ាងតិចណាស់នៅកម្រិតថ្នាក់ឃុំ) គួរចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍។

មុននឹងចុះបេសកកម្ម សហគមន៍គួររៀបចំនូវឯកសារមួយសម្រាប់កត់ត្រាទុកនូវរាល់ទំនៀមទម្លាប់បុរាណ និងការកាន់ខ្ជាប់ប្រពៃណីនានា។ ឧទាហរណ៍ វាអាចដូចជាការប្រើប្រាស់ភាសាណាមួយ ឬច្រើន ពិធីបូជាតាមបែបប្រពៃណី ពិធីបុណ្យសព ពិធីរៀបមង្គលការ និងពិធីផ្សេងៗទៀតដែលសហគមន៍បានរៀបចំជាទៀងទាត់ ឧបករណ៍តន្ត្រីបុរាណ ការប្រកបរបរកសិកម្មតាមប្រពៃណី ជាដើម ។ល។ ក្រសួងអភិវឌ្ឍន៍ជនបទធ្វើការវាយតម្លៃទៅលើរបៀបរបបសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច ដោយរួមបញ្ចូលទាំងការគ្រប់គ្រងដីសមូហភាព ហើយធ្វើការផ្ទៀងផ្ទាត់នូវសុឆន្ទៈរបស់សមាជិកសហគមន៍ ដែលត្រូវធ្វើការពិចារណាថាជា "ជនជាតិដើមភាគតិច"។

លក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ ដែលត្រូវយកមកពិចារណាចំពោះសហគមន៍ជនជាតិដើមភាគតិច មានចែងនៅក្នុងមាត្រា២៣ នៃច្បាប់ភូមិបាលឆ្នាំ ២០០១៖

"ជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់តាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។"

បន្ថែមពីលើនេះ ចំណុច ខ.១-៦ នៅក្នុងសារាចរលេខ ០៩៧៤/០៩ កអជ របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានចែងលម្អិតថាសហគមន៍ជនជាតិដើមភាគតិចត្រូវ៖

- ធ្វើស្វ័យកំណត់អត្តសញ្ញាណ និងទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន
- មានភាសាផ្ទាល់ខ្លួន ឬបាត់បង់ មាន ឬគ្មានអក្សរសរសេរ
- មានអាជ្ញាធរប្រពៃណី ដូចជា ចាស់ភូមិ មេកន្ទ្រាញ ឬយន្តការធ្វើសេចក្តីសម្រេចចិត្តជាសមូហភាព
- មានដីសហគមន៍ចំនួនប្រាំប្រភេទ (ដីព្រៃអារក្ស ដីកប់ខ្មោច ដីចម្ការវិលជុំ ឬដីបម្រុង ដីដាំដំណាំជាក់ស្តែង និងដីលំនៅឋាន)។

នៅក្នុងរយៈពេលបេសកកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ សន្និបាតសហគមន៍មួយគួរត្រូវបានធ្វើឡើង ដោយមានការចូលរួមពីសមាជិកសហគមន៍ទាំងអស់ អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងមកពីសហគមន៍ជិតខាង។ សន្និបាតត្រូវមានការដាក់បញ្ចូលនូវសុន្ទរៈកថាពីសំណាក់អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងសហគមន៍ ដោយបង្ហាញនូវការប្តេជ្ញាចិត្តឆ្ពោះទៅការអភិវឌ្ឍសហគមន៍។ គណៈកម្មាធិការសហគមន៍គួររៀបចំនូវកំណត់ហេតុកិច្ចប្រជុំមួយសម្រាប់សកម្មភាពនេះ ដោយរួមមានទាំងបញ្ជីរាយនាមអ្នកចូលរួមទាំងអស់ទៀតផង។

ប្រសិនបើក្រសួងអភិវឌ្ឍន៍ជនបទសន្និដ្ឋានថាសហគមន៍មានលក្ខណៈសម្បត្តិជា "សហគមន៍ជនជាតិដើមភាគតិច" នោះក្រសួងនឹងចេញវិញ្ញាបនបត្រទទួលស្គាល់។ វិញ្ញាបនបត្រនេះចុះហត្ថលេខាដោយក្រសួងអភិវឌ្ឍន៍ជនបទ ហើយសេចក្តីចម្លងវាគួរត្រូវបានផ្ញើទៅឲ្យក្រសួងពាក់ព័ន្ធទាំងអស់ (រួមមានក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ល។)។

បន្ទាប់មក ពិធីប្រគល់វិញ្ញាបនបត្រឲ្យសហគមន៍គួរត្រូវបានរៀបចំឡើងដោយមន្ទីរអភិវឌ្ឍន៍ជនបទ។ អ្នកតំណាងពីក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល រួមទាំងសហគមន៍នៅមូលដ្ឋានដែលពាក់ព័ន្ធ គួរត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងពិធីនេះ។

# ដំណាក់កាលទី២៖

## ក្រសួងមហាផ្ទៃ
## ការចុះបញ្ជីទទួលស្គាល់ជាផ្លូវការ
## សហគមន៍ជនជាតដើមភាគតច
## ដើម្បីទទួលបាននូវសិទ្ធិជា
## “ នីតបុគ្គល ”

## សេចក្តីផ្តើម

សហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា មិនស្ថិតនៅក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ០៨១៥/០១០នស/រកម/ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ នោះឡើយ។

ច្បាប់ភូមិបាលឆ្នាំ ២០០១ បានទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច នៅព្រះរាជាណាចក្រកម្ពុជាក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លីជាកម្មសិទ្ធិសមូហភាព។ ឯកសារបឋមស្តីពីក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីឆ្នាំ២០០២ បានលើកឡើងអំពី "លក្ខណៈពិសេសខាងសង្គមលើការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច និងប្រការដែលមានវិវាទជាញឹកញាប់ពាក់ព័ន្ធនឹងដីធ្លីដែលពួកគាត់រស់នៅ"។ ដូច្នេះការរៀបចំក្របខណ្ឌគតិយុត្តសមស្របមួយសម្រាប់ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ជាប្រការសំខាន់ដើម្បីពង្រឹងការគ្រប់គ្រងដីធ្លី ព្រៃឈើ និងធនធានធម្មជាតិដ៏ទៃទៀតឲ្យមាននិរន្តរភាព និងមានតុល្យភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងធានាថែរក្សាបាននូវវប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីល្អរបស់សហគមន៍ជនជាតិដើមភាគតិច។

ចំពោះការកំណត់អត្តសញ្ញាណ នៃការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា គឺអនុលោមតាមច្បាប់ភូមិបាលឆ្នាំ២០០១ និងផ្អែកលើគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ព្រមទាំងគោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិចដែលបានចងក្រងបង្កើតជា "នីតិបុគ្គល" គឺត្រូវចុះបញ្ជីទទួលស្គាល់ជាផ្លូវការ នៅក្រសួងមហាផ្ទៃ។

ដូច្នេះការកំណត់អត្តសញ្ញាណ នៃការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គឺមានក្រសួងពាក់ព័ន្ធចំនួន៣(បី) ដែលត្រូវបានកំណត់ឲ្យបំពេញកិច្ចការនេះ រួមមាន៖ (១)ក្រសួងអភិវឌ្ឍន៍ជនបទ (២)ក្រសួងមហាផ្ទៃ និង(៣)ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## អំពីសកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្ត៖

**ជំហានទី ១៖** អំពីការរៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងរៀបចំសមាសភាពគណៈកម្មាធិការសហគមន៍
**ជំហានទី ២៖** អំពីការពិនិត្យគោលបំណង និងឆន្ទៈរបស់សមាជិកសហគមន៍
**ជំហានទី ៣៖** អំពីការរៀបចំកិច្ចប្រជុំពេញអង្គអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍
**ជំហានទី ៤៖** អំពីការរៀបចំពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ជាផ្លូវការ
**ជំហានទី ៥៖** អំពីការចុះបញ្ជីទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជា **(នីតិបុគ្គល)**

## ជំហានទី១ ៖ អំពីការរៀបចំសេចក្ដីព្រាងលក្ខន្តិកៈ និងរៀបចំសមាសភាពគណៈកម្មាធិការសហគមន៍

បន្ទាប់ពីទទួលបានការកំណត់អត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈលិខិតបញ្ជាក់ដោយក្រសួងអភិវឌ្ឍន៍ជនបទរួចហើយ សហគមន៍ជនជាតិដើមភាគតិចត្រូវបន្តរៀបចំឲ្យមាន៖ (១).បញ្ជីសមាជិកសហគមន៍រួមមួយ (២).សេចក្ដីព្រាងលក្ខន្តិកៈ និង(៣).ការជ្រើសរើសសមាសភាពគណៈកម្មាធិការសហគមន៍ ក្នុងគោលបំណងដើម្បីស្នើសុំការពិនិត្យ សម្រេចអនុម័តពីសម្ហភាពសហគមន៍ទាំងមូល។ ចំពោះកិច្ចការនេះសហគមន៍ជនជាតិដើមភាគតិច មិនអាចដំណើរការរៀបចំដោយខ្លួនឯងបានឡើយ ដោយសារមានបញ្ហាខាងផ្នែកសមត្ថភាព និងកត្តាចំណេះដឹង ជារួមក្នុងការអនុវត្តកន្លងមកកិច្ចការនេះត្រូវបានសម្របសម្រួលផ្នែកបច្ចេកទេសដោយមន្ត្រីគម្រោងរបស់អង្គការដៃគូ អ្នកពាក់ព័ន្ធនានា ព្រមទាំងមានការគាំទ្រពីរដ្ឋបាលខេត្ត (ទីចាត់ការអន្តរវិស័យ) រួមជាមួយអាជ្ញាធរឃុំ/សង្កាត់ ជាអ្នកជួយរៀបចំដោយផ្ទាល់ជាមួយសហគមន៍។

## ជំហានទី២ ៖ អំពីការពិនិត្យគោលបំណង និងឆន្ទៈរបស់សមាជិកសហគមន៍

ការពិនិត្យអំពីគោលបំណង និងឆន្ទៈរបស់សមាជិកសហគមន៍ត្រូវបានរៀបចំតាមរយៈយន្តការមួយដែលមានការចូលរួមគាំទ្រដោយអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តសាមី និងមានកិច្ចសហការពីអង្គការដៃគូ អ្នកពាក់ព័ន្ធនានា បានជួយគាំទ្រ និងរៀបចំដំណើការកិច្ចប្រជុំរបស់សមាជិកសហគមន៍ ដើម្បីពិនិត្យលើកិច្ចការមួយចំនួនដូចជា៖

១. ពិនិត្យឡើងវិញអំពីគោលបំណង និងឆន្ទៈ ការមូលមតិឯកភាពគ្នារបស់សហគមន៍ទាំងមូល ក្នុងការសម្រេចចិត្តបន្តអនុវត្តនីតិវិធីចុះបញ្ជីសហគមន៍ដើម្បីទទួលបានសិទ្ធិស្របច្បាប់ជា (នីតិបុគ្គល)
២. ពិនិត្យណែនាំនីតិវិធី សំណុំបែបបទសម្រាប់ចុះបញ្ជី ក្នុងករណីពិនិត្យឃើញមានកំហុសឆ្គង ឬចំណុចខ្វះខាតនៃសំណុំឯកសារ អ្នកពាក់ព័ន្ធនឹងធ្វើការកត់សម្គាល់សម្របសម្រួលដើម្បីពិនិត្យកែតម្រូវឡើងវិញ
៣. ពិនិត្យខ្លឹមសារនៃសេចក្ដីព្រាងលក្ខន្តិកៈរបស់សហគមន៍ឡើងវិញ មុននឹងដាក់សុំការសម្រេចអនុម័តពីសម្ហភាពនៅក្នុងកិច្ចប្រជុំពេញអង្គរបស់សហគមន៍។

ដោយឡែកចំពោះទម្រង់ និងខ្លឹមសារនៃសេចក្ដីព្រាងលក្ខន្តិកៈ និងសំណុំឯកសារពាក់ព័ន្ធរបស់សហគមន៍នីមួយៗ គឺមានភាពប្រហាក់ប្រហែលគ្នា ដែលអាចឲ្យសហគមន៍ដទៃទៀតយកធ្វើជាគំរូបាន ដោយគ្រាន់តែធ្វើការកែសម្រួលត្រង់ចំណុចមួយចំនួនដូចជា៖ ឈ្មោះសហគមន៍ អាសយដ្ឋាននៃទីស្នាក់ការ អត្តសញ្ញាណ ឬចំណុចតិចតួចបន្ថែមលើសពីនេះ។[10]

---

[10] យោងតាមទម្រង់លិខិតបទដ្ឋានរបស់ក្រសួងមហាផ្ទៃ មាតិកាខាងក្រោមត្រូវដាក់បញ្ចូលនៅក្នុងលក្ខន្តិកៈ៖
- ជំពូកទី ១ ៖ អំពីឈ្មោះ អាសយដ្ឋាន អត្តសញ្ញាណ និងវិសាលភាព
- ជំពូកទី ២ ៖ គោលបំណង និងទិសដៅ
- ជំពូកទី ៣ ៖ រចនាសម្ព័ន្ធដឹកនាំ តួនាទី និងភារកិច្ច
- ជំពូកទី ៤ ៖ ការចូលជាសមាជិក ការបាត់បង់ និងការសុំចូលជាសមាជិកថ្មី
- ជំពូកទី ៥ ៖ អំពីអង្គប្រជុំ
- ជំពូកទី ៦ ៖ អំពីទ្រព្យសម្បត្តិសហគមន៍ និងការគ្រប់គ្រង
- ជំពូកទី ៧ ៖ អំពីវិសោធនកម្មលក្ខន្តិកៈ និងការរំលាយសហគមន៍
- ជំពូកទី ៨ ៖ អវសានប្បញ្ញត្តិ

## ជំហានទី៣ ៖ អំពីការរៀបចំកិច្ចប្រជុំពេញអង្គដើម្បីសម្រេចអនុម័ត សេចក្តីព្រាងលក្ខន្តិកៈ និងការជ្រើសតាំងគណៈកម្មាធិការសហគមន៍

សហគមន៍ជនជាតិដើមភាគតិច ត្រូវសម្របសម្រួលរៀបចំឲ្យមានកិច្ចប្រជុំមួយ ក្នុងគោលបំណងពិនិត្យ និងពិភាក្សាដើម្បីសម្រេចអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ ព្រមទាំងជ្រើសតាំងគណៈកម្មាធិការសហគមន៍ សម្រាប់បំពេញទម្រង់បែបបទចុះបញ្ជីនៅក្រសួងមហាផ្ទៃ ។ នៅដំណាក់កាលនេះ តំណាងស្ថាបនិកសហគមន៍ត្រូវធ្វើលិខិតស្នើសុំទៅ អភិបាលនៃគណៈអភិបាលខេត្តសាមីតាមរយៈមេឃុំ និងអភិបាលស្រុក ក្នុងគោលបំណងដើម្បីស្នើសុំអញ្ជើញអភិបាលខេត្ត ឬតំណាងចូលរួមជាអធិបតី និងស្នើសុំអញ្ជើញអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមជាភ្ញៀវកិត្តិយស មូលហេតុដោយសារសាមីសហគមន៍ផ្ទាល់ខ្វះខាតមធ្យោបាយ និងខ្វះការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ ដោយកំណត់ពេលវេលា ទីកន្លែង និងរបៀបវារៈច្បាស់លាស់។ ជារឿយៗក្រោយពេលដែលរដ្ឋបាលខេត្តរៀបចំលិខិតអញ្ជើញអ្នកពាក់ព័ន្ធរួចរាល់ អង្គការដៃគូរតែងតែជួយចែកលិខិតអញ្ជើញនេះជំនួសសហគមន៍ ដែលសមាសភាពចូលរួមពីអាជ្ញាធរមូលដ្ឋានឃុំ/ស្រុក/ខេត្ត/ក្រសួងមហាផ្ទៃ គឺជាតួអង្គដ៏សំខាន់ ព្រោះរាល់សំណុំឯកសារដែលត្រូវរៀបចំដាក់មកក្រសួងមហាផ្ទៃ ត្រូវមានការបញ្ជាក់បញ្ជូនពីអាជ្ញាធរទាំងនោះ ចំពោះមន្ទីរ វិស័យពាក់ព័ន្ធគួរត្រូវបានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស និងជាសាក្សីនៅក្នុងដំណើរការប្រជុំពេញអង្គនេះ។ ចំណែកសមាជិកគ្រួសារសហគមន៍ត្រូវធ្វើការចាត់តំណាងគ្រួសាររបស់ខ្លួនដើម្បីចូលរួមពិនិត្យ និងអនុម័តលើរបៀបវារៈនៃកិច្ចប្រជុំពេញអង្គរបស់សហគមន៍នេះ គប្បីកុំឲ្យអាក់ខាន ។

**កិច្ចប្រជុំពេញអង្គរបស់សហគមន៍គួរមានរបៀបវារៈដូចខាងក្រោម៖**

១. ពិធីស្វាគមន៍តាមប្រពៃណី របាំ និងចម្រៀង
២. មតិស្វាគមន៍ដោយអ្នកតំណាងសហគមន៍
៣. មតិចាប់អារម្មណ៍បើកអង្គប្រជុំដោយតំណាងរដ្ឋបាលខេត្ត ឬរដ្ឋបាលស្រុក។
៤. ការពិភាក្សា និងឯកភាពទៅលើរបៀបវារៈនៃកិច្ចប្រជុំពេញអង្គ (ការអានសេចក្តីព្រាងលក្ខន្តិកៈឮៗជាភាសាខ្មែរ ដោយមានការពន្យល់ជាភាសាដើមកំណើតរបស់សហគមន៍។ អ្នកចូលរួមគ្រប់រូបត្រូវយល់ព្រមដោយច្បាស់លាស់ចំពោះប្រការនីមួយៗ ហើយធ្វើឡើងដោយការលើកដៃ)។
៥. ការឡើងធ្វើបទបង្ហាញ (ការឡើងបញ្ចេញមតិ) ដោយសមាជិកសហគមន៍។
៦. មតិប្តេជ្ញាចិត្តរបស់តំណាងសហគមន៍។
៧. ចំណាប់អារម្មណ៍បិទ ដោយតំណាងរដ្ឋបាលខេត្ត ឬរដ្ឋបាលស្រុក។

## ជំហានទី៤ ៖ អំពីការរៀបចំពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ជាផ្លូវការ

បន្ទាប់ពីសហគមន៍បានប្រជុំអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងជ្រើសតាំងគណៈកម្មាធិការសហគមន៍រួច ប្រធានសហគមន៍ត្រូវរៀបចំចងក្រងប្រមូល និងបំពេញសំណុំឯកសារចំនួន៦ (ប្រាំមួយ) រួមមាន៖

១. បញ្ជីសមាជិករួម ចំនួន ២(ពីរ)ច្បាប់ (ដោយមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់)
២. លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ដោយក្រសួងអភិវឌ្ឍជនបទ
៣. លក្ខន្តិកៈសហគមន៍ ចំនួន ២(ពីរ)ច្បាប់
៤. ប្រវត្តិរូបសង្ខេបរបស់គណៈកម្មាធិការសហគមន៍ ក្នុងម្នាក់ៗ ចំនួន ២(ពីរ)ច្បាប់ ដោយភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬឯកសារពាក់ព័ន្ធនានា(ច្បាប់ថតចម្លង)
៥. សេចក្តីសម្រេចរបស់ឃុំស្តីពីការទទួលស្គាល់លក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ ចំនួន ២ (ពីរ)ច្បាប់
៦. សំណើសុំចុះឈ្មោះសហគមន៍ទៅក្រសួងមហាផ្ទៃ ចំនួន ២(ពីរ)ច្បាប់។([11])

**ពាក់ព័ន្ធនឹងការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់នោះ** គឺតម្រូវឲ្យប្រធានសហគមន៍ ធ្វើសំណើជាលាយលក្ខណ៍អក្សរជូនទៅក្រុមប្រឹក្សាឃុំ/សង្កាត់សាមី (ដោយជូនភ្ជាប់ទៅជាមួយនូវកំណត់ហេតុកិច្ចប្រជុំពេញអង្គ រួមទាំងបញ្ជីវត្តមាន និងបញ្ជីឈ្មោះសមាជិកគណៈកម្មាធិការសហគមន៍ទាំងអស់) ដើម្បីស្នើសុំឲ្យមេឃុំ ឬចៅសង្កាត់ ធ្វើការពិនិត្យ និងចេញសេចក្តីសម្រេចទទួលស្គាល់លក្ខន្តិកៈ និងគណៈកម្មាធិការរបស់សហគមន៍។

បន្ទាប់ពីសហគមន៍បានរៀបចំនូវសំណុំឯកសារទាំង៦(ប្រាំមួយ) ខាងលើ បានគ្រប់គ្រាន់រួចរាល់ និងត្រឹមត្រូវហើយ សហគមន៍សាមីត្រូវបញ្ជូនសំណុំឯកសារទាំងអស់ ជូនទៅមេឃុំ/ចៅសង្កាត់ អភិបាលក្រុង/ស្រុក និងអភិបាលខេត្ត ដើម្បីស្នើសុំចុះហត្ថលេខាបញ្ជាក់ បន្ទាប់មកត្រូវបញ្ជូនមកក្រសួងមហាផ្ទៃ។ ជាក់ស្តែងកន្លងមក ចំពោះការរៀបចំនូវសំណុំឯកសារទាំងនេះគឺទទួលបាននូវការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា ព្រមទាំងមានការចូលរួមសហការយ៉ាងល្អរបស់មន្ត្រីរដ្ឋបាលខេត្ត មន្ត្រីអង្គភាពជំនាញ អាជ្ញាធរ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំហានទី៥ ៖ អំពីការចុះបញ្ជីទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជា( នីតិបុគ្គល )

បន្ទាប់ពីពាក្យស្នើសុំចុះបញ្ជីរបស់សហគមន៍ និងឯកសារពាក់ព័ន្ធនានា ត្រូវបានរៀបចំបញ្ចប់រួចរាល់ជាស្ថាពរហើយនោះ រដ្ឋបាលខេត្តដោយមានទីចាត់ការអន្តរវិស័យ ដែលជាសេនាធិការឲ្យអភិបាលនៃគណៈអភិបាលខេត្ត មានតួនាទីក្នុងការសម្របសម្រួលទំនាក់ទំនងបញ្ជូនពាក្យសុំចុះបញ្ជីរបស់សហគមន៍ជនជាតិដើមភាគតិច និងសំណុំឯកសារពាក់ព័ន្ធនានាជូនមកក្រសួងមហាផ្ទៃ (អគ្គនាយកដ្ឋានរដ្ឋបាល) ដើម្បីធ្វើការពិនិត្យសំណុំឯកសារ និងសម្រេចចុះឈ្មោះសហគមន៍ជនជាតិដើមភាគតិចនោះទៅក្នុងបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការ នៅក្រសួងមហាផ្ទៃ។

---

([11]) បញ្ជាក់៖ ជាទូទៅសហគមន៍ ត្រូវរៀបចំឯកសារទាំងនេះ យ៉ាងតិចចំនួន ៥ (ប្រាំ)ច្បាប់ ដោយរក្សាទុកនៅសាលាឃុំ/សង្កាត់ ចំនួន១(មួយ)ច្បាប់ សាលាក្រុង/ស្រុក ចំនួន១(មួយ)ច្បាប់ សាលាខេត្តចំនួន ១(មួយ)ច្បាប់ និង ចំនួន២(ពីរ)ច្បាប់ទៀត ត្រូវផ្ញើជូនទៅក្រសួងមហាផ្ទៃ។

ក្រោយពេលដែលក្រសួងមហាផ្ទៃ បានសម្រេចចុះឈ្មោះសហគមន៍ជនជាតិដើមភាគតិចទៅក្នុងបញ្ជីសហគមន៍នៅក្រសួងមហាផ្ទៃ រួចហើយនោះ គឺមានន័យថា សហគមន៍ជនជាតិដើមភាគតិចនោះ ទទួលបាននូវសិទ្ធិគ្រប់គ្រាន់ស្របច្បាប់ក្នុងការដាក់ពាក្យសុំចុះបញ្ជីដីធ្លីជាសមូហភាព ដោយទទួលបានឋានៈជានីតិបុគ្គល។

ដោយឡែកចំពោះលិខិត និងសំណុំឯកសាររបស់សហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានសម្រេចចុះឈ្មោះក្នុងបញ្ជីជាផ្លូវការរួចហើយ ក្រសួងមហាផ្ទៃនឹងធ្វើលិខិតជម្រាបទៅ អភិបាលនៃគណៈអភិបាលខេត្ត ដើម្បីចាត់តំណាងរដ្ឋបាលខេត្ត ឬរដ្ឋបាលស្រុក និងអញ្ជើញដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អ្នកពាក់ព័ន្ធនានា ចូលរួមក្នុងពិធីប្រគល់ជូនទៅសហគមន៍ជនជាតិដើមភាគតិច តាមរយៈអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលរបស់សហគមន៍នីមួយៗ (ទីតាំងសហគមន៍ផ្ទាល់)។

# ដំណាក់កាលទី២.៥៖

## សហគមន៍ជនជាតិដើមភាគតិច ដាក់ពាក្យសុំចុះបញ្ជី
## ដីកម្មសិទ្ធិសមូហភាពទៅ
## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីផ្តើម

នៅពេលដែលសហគមន៍ត្រូវបានកំណត់អត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិច និងត្រូវបានទទួលស្គាល់ជានីតិបុគ្គលរួចហើយនោះ ដំណាក់កាលចុងក្រោយគឺការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ៨៣ អនក្រ បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៩ បានផ្តល់ឲ្យនូវទម្រង់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដែលតម្រូវឲ្យមានការភ្ជាប់ជាមួយនូវឯកសារមួយចំនួន ហៅកាត់ថា "ឯកសារបឋម"។ ឯកសារភ្ជាប់ទាំងនេះមានដូចជា ប្លង់ក្បាលដីមិនផ្លូវការ (ផែនទីបឋម) ដែលត្រូវបានដាក់បញ្ចូលនៅក្នុងពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព និងបទបញ្ជាផ្ទៃក្នុងដែលបានអនុម័តដោយសហគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធជាមួយនឹងផែនការការគ្រប់គ្រងដី និងយន្តការដោះស្រាយវិវាទ។ ដោយហេតុថាឯកសារទាំងនេះត្រូវបានរៀបចំ និងភ្ជាប់អមរួចរាល់ហើយជាមួយនឹងពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅឲ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នោះឯកសារទាំងនេះ ជាទូទៅ ត្រូវបានកំណត់ថាជាដំណាក់កាល ២.៥។ ការរៀបចំឯកសារបឋមទាំងនេះមានបញ្ហាប្រឈមច្រើន ហេតុដូច្នេះហើយមានការតម្រូវឲ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសបន្ថែមដល់សហគមន៍ជនជាតិដើមភាគតិចពីសំណាក់អាជ្ញាធរពាក់ព័ន្ធ។ នៅក្នុងស្ថានភាពដែលអាជ្ញាធរពាក់ព័ន្ធមិនអាចជួយបាន នោះដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិលអាចជួយបំពេញកង្វះខាតនេះបាន។ ពាក្យស្នើសុំចុងក្រោយគួរត្រូវបានពិនិត្យដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត មុនធ្វើរបាយការណ៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធ្វើផែនការអនុវត្តការងារចុះបញ្ជីដី និងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច។

**សកម្មភាពតម្រូវឲ្យអនុវត្តនៅក្នុងដំណាក់កាលទី២.៥ ៖**

**ជំហានទី ១៖** សហគមន៍ជនជាតិដើមភាគតិច រៀបចំតាក់តែងបទបញ្ជាផ្ទៃក្នុង
**ជំហានទី ២៖** ការប្រមូលទិន្នន័យនិងផលិតផែនទីបឋមដោយកំណត់ព្រំប្រទល់ប្រភេទដីរបស់សហគមន៍
**ជំហានទី ៣៖** សហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ជំហានទី១ ៖ សហគមន៍ជនជាតិដើមភាគតិច រៀបចំតាក់តែងបទបញ្ជាផ្ទៃក្នុង[12]

បទបញ្ជាផ្ទៃក្នុងមិនដូចគ្នាទៅនឹងលក្ខន្តិកៈទេ។ លក្ខន្តិកៈផ្តល់នូវក្របខ័ណ្ឌគ្រប់គ្រងទៅលើបទបញ្ជាផ្ទៃក្នុង ហើយបទបញ្ជាផ្ទៃក្នុងយោងមកលើលក្ខន្តិកៈវិញ។ បទបញ្ជាផ្ទៃក្នុងគឺជាបញ្ជាផ្ទៃក្នុងរបស់សហគមន៍ និងមានតួនាទីធានានូវការប្រើប្រាស់ប្រកបដោយសមធម៌ទៅលើដីសម្ហូហភាព និងការគ្រប់គ្រងដីទាំងនោះ និងដោះស្រាយជម្លោះផ្ទៃក្នុងណាមួយ។ បទបញ្ជាផ្ទៃក្នុងទាំងនេះក៏ជួយថែរក្សានូវអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់សហគមន៍ផងដែរ តាមរយៈការប្រើប្រាស់ដីប្រកបដោយចីរភាព ការគ្រប់គ្រងដី ក៏ដូចជាធនធានធម្មជាតិ ដូច្នេះវានឹងជួយរួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ។

បទបញ្ជាផ្ទៃក្នុងមានសារៈសំខាន់ណាស់ ពីព្រោះវាជាអ្នកគ្រប់គ្រងទំនាក់ទំនងរបស់សហគមន៍ជាមួយនឹង "អ្នកខាងក្រៅ" ដែលមានដូចជា អ្នកភូមិជាជនជាតិដើមភាគតិច ដែលបានសម្រេចចិត្តមិនចូលរួមជាសមាជិកសហគមន៍ជនជាតិដើមភាគតិច ឬក៏ជាមួយនឹងប្រជាជនខ្មែរ ដែលរស់នៅក្នុងភូមិដែលមិនអាចចូលរួមជាសមាជិករបស់សហគមន៍បាន។ ឧទាហរណ៍ ប្រសិនបើមានអ្នកភូមិត្រឹមតែចំនួន ៦០ ភាគរយដែលបានសម្រេចចិត្តចូលរួមជាមួយនឹងសហគមន៍ជនជាតិដើមភាគតិច នោះជាការសំខាន់ណាស់ដែលត្រូវកំណត់ថាតើអ្នកមិនមែនជាសមាជិក អាចប្រើប្រាស់ដីសម្ហូហភាព តំបន់ព្រៃអារក្ស និងវាលកប់សពរបស់ពួកគេបានក្នុងកម្រិតណា ពីព្រោះ ជាគោលការណ៍មានតែសមាជិករបស់សហគមន៍ជនជាតិដើមភាគតិចប៉ុណ្ណោះ ដែលជាអ្នកកាន់កាប់សិទ្ធិត្រឹមត្រូវទៅលើដីដែលបាគ្រប់គ្រងជាសម្ហូហភាពនោះ។

ការតាក់តែងបទបញ្ជាផ្ទៃក្នុងគួរដាក់បញ្ចូលនូវកិច្ចប្រជុំរវាងគណៈកម្មាធិការសហគមន៍ និងចាស់ទុំនៅក្នុងសហគមន៍ ដើម្បីរៀបចំសេចក្តីព្រាង(លក្ខន្តិកៈ)លើកទីមួយនេះ។ អាជ្ញាធរមូលដ្ឋាន រួមមានប្រធានភូមិ និងមេឃុំ គួរចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ បទបញ្ជាផ្ទៃក្នុងត្រូវទទួលស្គាល់ជាផ្លូវការដោយភាគីពាក់ព័ន្ធ។ ការព្រាងបទបញ្ជាផ្ទៃក្នុងគួរត្រូវបានគាំទ្រនិងដឹកនាំដោយមន្ទីរអភិវឌ្ឍន៍ជនបទ។ នៅក្នុងការអនុវត្តនាពេលបច្ចុប្បន្ននេះ ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល ជារឿយៗក៏បានគាំទ្រចំពោះដំណើរការនេះដែរ។ នៅក្នុងពេលប្រជុំរៀបចំសេចក្តីព្រាងនេះ ត្រូវអានបទបញ្ជាផ្ទៃក្នុងដែលបានតាក់តែងឮៗ មួយប្រយោគម្តងៗ នៅក្នុងពេលវេលាណាមួយ ដោយអ្នកសម្របសម្រួល។ គណៈកម្មាធិការសហគមន៍ត្រូវរៀបចំកំណត់ហេតុកិច្ចប្រជុំសម្រាប់សកម្មភាពនេះ រួមមានបញ្ជីរាយនាមអ្នកចូលរួមទាំងអស់ និងលទ្ធផលនៃកិច្ចប្រជុំផងដែរ។

ដោយហេតុថាសហគមន៍ជនជាតិដើមភាគតិចមានលក្ខណៈខុសៗគ្នា ដោយសារកត្តាទំហំផ្ទៃដីប្រភេទដីដែលមាននៅលើដីសម្ហូហភាព ចំនួនប្រជាជន និងជាយថាហេតុ អាចជាកត្តាការចូលរួមចំណែករបស់សមាជិកសហគមន៍ នៅក្នុងការគាំទ្រការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសម្ហូហភាពនោះជាការសំខាន់ណាស់ ដែលសហគមន៍ជនជាតិដើមភាគតិចនីមួយៗត្រូវកំណត់បទបញ្ជាផ្ទៃក្នុង

---

12 គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច(NPDIP), ចំណុច ៥.២ បានចែងថា ៖ "ការអនុវត្តសិទ្ធិម្ចាស់កម្មសិទ្ធិ ដែលពាក់ព័ន្ធជាមួយនឹងអចលនទ្រព្យរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដី ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការសហគមន៍ និងនៅក្រោមយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍ ស្របតាមប្រពៃណី លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងត្រូវដាក់ឲ្យស្ថិតនៅក្រោមច្បាប់ទូទៅដែលពាក់ព័ន្ធជាមួយនឹងអចលនទ្រព្យ។" សំគាល់៖ តាមការអនុវត្តជាក់ស្តែង ក្រសួង/មន្ទីរអភិវឌ្ឍន៍ជនបទនិង/ឬអង្គការគាំទ្រ ជាអ្នកជួយសម្របសម្រួលក្នុងការតាក់តែងបទបញ្ជាផ្ទៃក្នុងនេះ។

ផ្ទាល់ខ្លួនឲ្យមានភាពបត់បែនតាមស្ថានភាព និងការចង់បានរបស់ខ្លួន។ ផ្ទុយពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងមានភាពខុសគ្នាច្រើនគួរសមរវាងសហគមន៍នីមួយៗ។ នៅក្នុងករណីមួយចំនួន បទបញ្ជាផ្ទៃក្នុងដែលមានស្រាប់របស់សហគមន៍នៅទីកន្លែងផ្សេង អាចចាត់ទុកជាគំរូមួយបានដែរ ប៉ុន្តែមិនត្រូវចម្លងទាំងស្រុងនោះទេ។ មួយវិញទៀត បទបញ្ជាផ្ទៃក្នុងត្រូវយកចិត្តទុកដាក់ឲ្យបានជិតដល់បំផុតទៅលើចំណាត់ថ្នាក់ប្រភេទដីរដ្ឋដែលកំពុងមានស្រាប់ ដូចជាភាពខុសគ្នារវាងតំបន់ការពារ និងការបែងចែកដីជាប្រភេទដីឯកជន និងដីសាធារណៈរបស់រដ្ឋ។

នៅពេលដែលសេចក្ដីព្រាងនៃបទបញ្ជាផ្ទៃក្នុងត្រូវបានរៀបចំរួចហើយ នោះគណៈកម្មាធិការសហគមន៍ ក៏ត្រូវរៀបចំនូវកិច្ចប្រជុំជាច្រើនលើកជាមួយសមាជិករបស់សហគមន៍ជនជាតិដើមភាគតិចដើម្បីព្រមព្រៀងទៅលើខ្លឹមសារបទបញ្ជាផ្ទៃ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងតំបន់ដីសម្ងហភាព និងធនធានធម្មជាតិ។ អ្នកសម្របសម្រួលត្រូវអញ្ជើញសមាជិកសហគមន៍ទាំងអស់ចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះ ដើម្បីអោយពួកគេបានលើកឡើងអំពីទុក្ខកង្វល់របស់ខ្លួន។

នៅក្នុងកិច្ចប្រជុំចុងក្រោយ ដែលត្រូវអនុម័តទៅលើខ្លឹមសារបទបញ្ជាផ្ទៃក្នុង នោះសេចក្ដីព្រាងចុងក្រោយនៃបទបញ្ជាផ្ទៃក្នុងនោះគួរអានម្ដងទៀតដោយអ្នកសម្របសម្រួល មួយប្រយោគម្ដងៗ។ នៅក្នុងកិច្ចប្រជុំនេះត្រូវអញ្ជើញរាល់សមាជិកសហគមន៍ទាំងអស់ឲ្យចូលរួម ហើយពួកគេទាំងអស់មានសិទ្ធិបន្ថែមអ្វីដែលមិនទាន់មាន ឬកែសម្រួលនូវអ្វីដែលពួកគេយល់ឃើញថាមិនជាប់ពាក់ព័ន្ធនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពួកគេ។ នៅពេលដែលសមាជិកសហគមន៍ទាំងអស់បានពិភាក្សា និងពិនិត្យរាល់ជំពូក និងកថាខ័ណ្ឌ នៃឯកសារបទបញ្ជាផ្ទៃក្នុងរួចហើយ នោះការឯកភាពស្ថាពរតាមរយៈការបោះឆ្នោត (សំឡេងភាគច្រើន) ត្រូវធ្វើឡើងតាមរយៈការលើកដៃ។ គណៈកម្មាធិការសហគមន៍ត្រូវរៀបចំលទ្ធផលនៃកិច្ចប្រជុំ និងបញ្ជីរាយនាមអ្នកចូលរួមទាំងអស់។

បន្ទាប់ពីសមាជិកសហគមន៍បានអនុម័តបទបញ្ជាផ្ទៃក្នុងរួចហើយ នោះបទបញ្ជាផ្ទៃក្នុងនេះត្រូវមានការទទួលស្គាល់ដោយក្រុមប្រឹក្សាឃុំ មុននឹងភ្ជាប់អមជាមួយនឹងពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសម្ងហភាពទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[13] ជាមួយគ្នានេះ ត្រូវចម្លងជូនអាជ្ញាធរមូលដ្ឋាន និងក្រសួងពាក់ព័ន្ធ។

## ជំហានទី២ ៖ ការប្រមូលទិន្នន័យ និងផលិតផែនទីបឋមដោយកំណត់ព្រំប្រទល់ប្រភេទដីរបស់សហគមន៍

### ក) ផែនទីគូរដោយដៃ

ពាក់ព័ន្ធនឹងសេចក្ដីព្រាងបទបញ្ជាផ្ទៃក្នុងនេះ និងនៅក្នុងការរៀបចំអនុវត្តការគូរផែនទីបឋម នោះសហគមន៍ និងមន្ត្រីជំនាញគួរផលិតផែនទីគូរដោយដៃ - ជាទូទៅហៅថា *ផែនទីគំនូសព្រាង-*

[13] អនុក្រឹត្យលេខ ៨៣ ៖ " សហគមន៍ត្រូវបានបង្កើតឡើងជាផ្លូវការជានីតិបុគ្គល ដែលមានបទបញ្ជាផ្ទៃក្នុងចែងអំពីការគ្រប់គ្រង និងការប្រើប្រាស់ដីសម្ងហភាព ព្រមទាំងមានការកំណត់នូវលក្ខខណ្ឌមួយចំនួន ដូចជាការគ្រប់គ្រងដីសម្ងហភាព និងការប្រើប្រាស់ដីផ្អែកតាមប្រភេទដី និងការផ្សះផ្សារនៅក្នុងកម្រិតសហគមន៍ នៅក្នុងករណីមានជម្លោះដោយសារការប្រើប្រាស់ដីប្រពៃណី។"

ដោយបង្ហាញអំពីព្រំប្រទល់ភូមិ និងប្រភេទនៃការប្រើប្រាស់ដីនៅលើផែនទីនោះផង ដោយមិនចាំបាច់រៀបរាប់លម្អិតអំពីទំហំផ្ទៃដី ដែលកំពុងស្នើសុំ ឬទីតាំងជាក់លាក់ឡើយ។ អ្នកសម្របសម្រួលអាចប្រើប្រាស់ក្រដាសផ្ទាំងធំដើម្បីគូរផែនទីគំនូសព្រាងនេះ ដែលគួរមានព្រំប្រទល់ភូមិ និងតំបន់ប្រើប្រាស់ដីខុសៗគ្នានៅក្នុងព្រំប្រទល់នោះ។ អ្នកសម្របសម្រួលក៏អាចប្រើប្រាស់ផែនទីតាមផ្កាយរណបដែលបោះពុម្ពចេញ ដើម្បីជួយឲ្យសមាជិកសហគមន៍អាចកំណត់ព្រំប្រទល់ និងផ្ទៃដីសហគមន៍របស់ពួកគេបាន។ ប្រធានភូមិ ចាស់ទុំក្នុងភូមិ សមាជិកគណៈកម្មាធិការសហគមន៍ អ្នកតំណាងមកពីភូមិជិតខាង និងសមាជិកក្រុមប្រឹក្សាឃុំ ដោយរួមទាំងលោកមេឃុំផង គួរចូលរួមនៅក្នុងសកម្មភាពគូរផែនទីដោយដៃនេះ។ របាយការណ៍កិច្ចប្រជុំត្រូវរៀបចំឡើង រួមមានឧបសម្ព័ន្ធបញ្ជីរាយនាមអ្នកចូលរួមទាំងអស់នៅក្នុងកិច្ចប្រជុំ។ នៅក្នុងការអនុវត្តពេលបច្ចុប្បន្ននេះ ជារឿយៗ ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិលគាំទ្រដល់ការផលិតផែនទីគំនូសព្រាងបឋមនេះ។

នៅពេលផែនទីគំនូសព្រាងបឋមនេះត្រូវបានបញ្ចប់ការគូររួចរាល់ហើយ នោះសហគមន៍គួររៀបចំកិច្ចប្រជុំមួយ ដើម្បីបញ្ជាក់អំពីការយល់ព្រមពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ទៅលើការកំណត់ព្រំប្រទល់ភូមិនៅលើផែនទី។ ការអនុវត្តក្នុងពេលបច្ចុប្បន្ននេះ ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល ជារឿយៗជាអ្នកផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់កិច្ចប្រជុំទាំងនេះ។ មេឃុំ ឬអភិបាលស្រុកគួរធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំនេះ ហើយអ្នកតំណាងមកពីភូមិជិតខាង និងអ្នកតំណាងមកពីក្រុមការងារដីរដ្ឋ (ស្ថាប័នថ្នាក់ក្រោមជាតិមានភារកិច្ចធ្វើការកំណត់អត្តសញ្ញាណដីរដ្ឋ ការគូរផែនទី និងការចាត់ចំណាត់ថ្នាក់ដី) សមាជិកគណៈកម្មាធិការសហគមន៍ ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ សមាជិកក្រុមប្រឹក្សាឃុំ (រួមទាំងលោកមេឃុំផង) និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀតក៏គួរចូលរួមនៅក្នុងកិច្ចប្រជុំនេះផងដែរ។ ដើម្បីបង្ហាញនូវការការយល់ព្រមរបស់ពួកគេទៅលើផែនទីរួមទាំងទៅលើព្រំប្រទល់ និងប្រភេទការប្រើប្រាស់ដីដែលបានបញ្ជាក់ពីខាងដើម នោះអ្នកចូលរួមគួរផ្តិតមេដៃរបស់ពួកគេនៅលើសន្លឹកផែនទី។ ក្រៅពីនេះ របាយការណ៍ជាលាយលក្ខណ៍អក្សរមួយស្តីពីកិច្ចប្រជុំនេះក៏គួរត្រូវបានរៀបចំឡើងដោយមន្ទីរអភិវឌ្ឍន៍ជនបទ និងចុះហត្ថលេខាដោយលោកមេឃុំផងដែរ។

## ខ. ផែនទីបឋម

នៅពេលនេះ ជំហានបន្ទាប់ដែលត្រូវធ្វើ គឺការបំលែងផែនទីគំនូសព្រាងទៅជាផែនទីឌីជីថលដែលអាចហៅម្យ៉ាងទៀតថា "ផែនទីបឋម" ដើម្បីឲ្យស្របគ្នាជាមួយនឹងអនុក្រឹត្យលេខ ៨៣ អនក្រ បក ចុះថ្ងៃទី ០៩ មិថុនា ២០០៩ ដែលតម្រូវឲ្យភ្ជាប់ (ផែនទីបឋម) អមជាមួយនឹងពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ផែនទីបឋមគួរបង្ហាញអំពីទីតាំង ទំហំ និងព្រំប្រទល់ ដែលបានកំណត់សម្រាប់ក្បាលដីនីមួយៗ ដែលបានដាក់បញ្ចូលទៅក្នុងពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ (ផែនទីបឋមនេះនឹងត្រូវបញ្ចប់ឲ្យបានរួចរាល់ចាត់ទុកជាប្លង់សុរិយោដីពេញលេញផ្លូវការ តែនៅក្រោយពេលពាក្យស្នើសុំត្រូវបានទទួលយក និងឯកភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប៉ុណ្ណោះ)។

អនុក្រឹត្យលេខ ៨៣អន.ក្រ បក ចុះថ្ងៃទី ០៩ មិថុនា ២០០៩ មិនបានចែងលម្អិតអំពីនីតិវិធីបច្ចេកទេសដែលតម្រូវឲ្យអនុវត្តសម្រាប់ការវាស់វែងដីសហគមន៍ និងការគូរផែនទីបឋមឡើយ។ យ៉ាងនេះក្តី

សៀវភៅបណ្តុះបណ្តាលស្តីពីការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្នុងឆ្នាំ២០១២ និងបានធ្វើបច្ចុប្បន្នភាពនៅក្នុងឆ្នាំ ២០១៦ បានកត់សម្គាល់ថាត្រូវតែមាននិយាមការតាមប្រព័ន្ធ GPS យ៉ាងហោចណាស់នៅតាមជ្រុងមួយចំនួននៃព្រំប្រទល់នៃក្បាលដីដែរ។ សម្រាប់គោលបំណងនេះ ក្រុមការងារទីវាលផ្សេងៗគ្នាត្រូវតែបង្កើតឡើងដើម្បីវាស់វែងដី និងកត់ត្រាទិន្នន័យតាម GPS។ ក្រុមការងារទីវាលគួរបញ្ចូលអ្នកតំណាងនានាមកពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក សមាជិកគណៈកម្មាធិការសហគមន៍ ចាស់ទុំក្នុងភូមិ ប្រធានភូមិពីសហគមន៍ជិតខាង និងសមាជិកក្រុមប្រឹក្សាឃុំ។ ក្រុមការងារទីវាលទាំងនេះត្រូវទទួលនូវការបណ្តុះបណ្តាលដោយបុគ្គលិកមានបទពិសោធន៍ពីការិយាល័យភូមិបាលស្រុក អំពីការប្រមូលទិន្នន័យ និងការប្រើប្រាស់ GPS របៀបសរសេររបាយការណ៍ពាក់ព័ន្ធ និងរបៀបបំពេញទម្រង់លិខិតប្រមូលទិន្នន័យ។ នៅក្នុងការអនុវត្តបច្ចុប្បន្ននេះ ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល ជាញឹកញាប់ ជាអ្នកគាំទ្រការបណ្តុះបណ្តាលនេះ។

នៅក្នុងអំឡុងពេលគូរផែនទីតាមប្រព័ន្ធ GPS ក្រុមការងារទីវាលគួរបោះបង្គោលព្រំប្រទល់ឲ្យបានច្បាស់លាស់នូវប្រភេទដីសហគមន៍នីមួយៗដែលមាននៅក្នុងសហគមន៍ ដូចជាតំបន់ព្រៃអារក្ស ដីកប់ខ្មោច ដីលំនៅឋាន ដីដាំដំណាំជាក់ស្តែង ដីចម្ការវិលជុំ និងដីសាធារណៈរបស់រដ្ឋ (ដូចដែលមានចែងនៅក្នុងមាត្រា៦ នៃអនុក្រឹត្យលេខ ៨៣) ក៏ដូចជាដីឯកជនដែលស្ថិតនៅក្នុងតំបន់របស់សហគមន៍ដែលត្រូវកាត់ចេញពីដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ជាទូទៅ ស្ទឹង ទន្លេ ជួរភ្នំ និងចំណុចសម្គាល់ផ្សេងៗទៀត ត្រូវប្រើប្រាស់ដើម្បីសម្គាល់ព្រំប្រទល់សហគមន៍។ ក្រុមការងារទីវាលក៏ត្រូវស្នើសុំទៅកាន់ក្រុមប្រឹក្សាឃុំ និងមន្ទីររៀបចំដែនដីខេត្ត ឲ្យផ្តល់នូវផែនទីរបស់ពួកគេ ដែលបង្ហាញអំពីព្រំប្រទល់រដ្ឋបាល និងរូបថតពីលើអាកាស ហើយនិងផែនទីឋានលេខា ដោយបង្ហាញនូវភូមិសាស្ត្រ និងទីតាំងពិតប្រាកដរបស់សហគមន៍ ដែលត្រូវបានរក្សាទុកជាឯកសារនៅក្រសួងមហាផ្ទៃ។

បន្ទាប់ពីបញ្ចប់ការគូរផែនទីតាមប្រព័ន្ធ GPS រួចហើយនោះ ផែនទីឌីជីថលនឹងត្រូវបានផលិតឡើងដោយបង្ហាញនូវព័ត៌មានដែលបានព្រមព្រៀងគ្នារវាងបណ្តាភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសពាក់ព័ន្ធនឹងព្រំប្រទល់រដ្ឋបាលនៅលើដី ទីតាំងដីសហគមន៍ និងទំហំដីដែលបានប្រើប្រាស់នៃដីរបស់សហគមន៍។ ការងារនេះអាចធ្វើឡើងបានដោយប្រើប្រាស់សូហ្វវែរ GIS កម្រិតស្តង់ដាធម្មតា និងតម្រូវឲ្យមានមន្ត្រីសុរិយោដីជំនាញធ្វើការងារនេះគួរគប្បីចូលរួមដោយ អង្គការដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិលចំពោះដំណើរការនេះ។ នៅពេលដែលបញ្ចប់ការផលិតផែនទីឌីជីថល សហគមន៍គួររៀបចំកិច្ចប្រជុំមួយដើម្បីផ្តល់សុពលភាពដល់ផែនទីនេះគួររៀបចំឡើងនោះ។ នៅក្នុងការអនុវត្តនាពេលបច្ចុប្បន្ន ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិល ជាទូទៅ ជាអ្នកគាំទ្រដល់ការរៀបចំកិច្ចប្រជុំនេះ។ កិច្ចប្រជុំនេះគួរអញ្ជើញសមាជិកគណៈកម្មាធិការសហគមន៍ទាំងអស់ ព្រឹទ្ធាចារ្យក្នុងភូមិ ប្រធានភូមិពីសហគមន៍ជិតខាង សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកតំណាងមកពីការិយាល័យភូមិបាលស្រុក និងក្រុមការងារដីរដ្ឋថ្នាក់ស្រុក។ ប្រសិនបើមានការមិនឯកភាពទៅលើផែនទីឌីជីថល នោះផែនទីនោះត្រូវកែសម្រួលតាមរយៈការប្រមូលទិន្នន័យថ្មី ហើយកិច្ចប្រជុំថ្មីទៀតត្រូវធ្វើឡើងរហូតដល់បណ្តាភាគីទាំងអស់ព្រមព្រៀងគ្នា។ ផែនទីបឋមមិនត្រូវដាក់បញ្ចូលនូវតំបន់ណាមួយដែលមានការទាមទារជាន់គ្នា ឬកំពុងមានជម្លោះជាមួយនឹងសហគមន៍ជិតខាង ឬជាមួយនឹងសម្បទានិកដីធ្លី ពីព្រោះថាការទាមទារជាន់គ្នា/ជម្លោះនេះ នឹងមិនអាចទទួលយកបានទេ យោងតាមដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ កំណត់ត្រាកិច្ច

ប្រជុំគួរត្រូវរៀបចំដោយការិយាល័យភូមិបាលស្រុក ដោយដាក់បញ្ចូលនូវលទ្ធផលនៃកិច្ចប្រជុំ និងបញ្ជីរាយនាមអ្នកចូលរួមទាំងអស់។ របាយការណ៍នេះគួរចុះហត្ថលេខាដោយលោកមេឃុំ ឬក្រុមប្រឹក្សាឃុំ។

ដោយផ្អែកលើមតិយោបល់ទាំងអស់ ដែលទទួលបាននៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នោះកំណែចុងក្រោយទៅលើផែនទីបឋមគួរធ្វើឡើងដោយមន្ត្រីសុរិយោដី។ នៅក្នុងការអនុវត្តបច្ចុប្បន្ន ដៃគូអភិវឌ្ឍន៍/អង្គការសង្គមស៊ីវិលជារឿយៗជាអ្នកគាំទ្រដល់ដំណើរការនេះ។ ផែនទីនេះត្រូវចុះហត្ថលេខាដោយសមាជិកគណៈកម្មាធិការសហគមន៍ និងអ្នកទាំងឡាយណាដែលជាអ្នកផលិតវា ហើយនិងមានតួនាទីជាភស្តុតាងដើម្បីគាំទ្រដល់ដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព របស់សហគមន៍ជនជាតិដើមភាគតិច។ ផែនទីបឋម នាពេលក្រោយមកទៀតនឹងត្រូវបានប្រើប្រាស់ដោយក្រុមការងារចុះវាស់វែងរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលថ្នាក់ខេត្ត ដើម្បីរៀបចំជាប្លង់សុរិយោដី (ប្លង់ក្បាលដី) ពេញលេញ។

## ជំហានទី៣ ៖ សហគមន៍ជនជាតដើមភាគតិចដាក់ពាក្យសុំចុះបញ្ជីដីសមូហភាពទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ពេលដែលការគូរផែនទីបឋម និងការតាក់តែងបទបញ្ជាផ្ទៃក្នុងត្រូវបានឯកភាពគ្នាផ្ទៃក្នុងក៏ដូចជាជាមួយនឹងភាគីពាក់ព័ន្ធពីខាងក្រៅ (ក្រុមប្រឹក្សាឃុំ និងសហគមន៍ជិតខាង) រួចរាល់ហើយ នោះសហគមន៍មានសិទ្ធិដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយមានឯកសារភ្ជាប់ចាំបាច់ទាំងអស់រួចរាល់ទៅកាន់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាមរយៈការិយាល័យភូមិបាលស្រុក ដែលបន្ទាប់មកនឹងបញ្ជូនពាក្យស្នើសុំនេះមកឲ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលថ្នាក់ខេត្ត។ ពេលដែលពាក្យស្នើសុំនេះត្រូវបានពិនិត្យមើលភាពពេញលេញរបស់វា (ឯកសារគ្រប់ចំនួន) និងពិនិត្យពិច័យដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលរួចហើយ នោះមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមុនធ្វើរបាយការណ៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងធ្វើផែនការអនុវត្តការងារចុះបញ្ជីដីនិងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច។

**ឯកសារភ្ជាប់ដែលត្រូវភ្ជាប់អមជាមួយនឹងពាក្យស្នើសុំ មានដូចខាងក្រោម ៖**

- លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដោយក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតពីក្រសួងមហាផ្ទៃដែលទទួលស្គាល់សហគមន៍ជានីតិបុគ្គល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ឯកភាពទៅលើការតែងតាំងគណៈកម្មាធិការសហគមន៍
- លក្ខន្តិកៈសហគមន៍
- បញ្ជីរាយនាមសមាជិកសហគមន៍ ដោយមានការផ្ទៀងផ្ទាត់ទៅលើបញ្ជីរាយនាមនោះពីសំណាក់លោកមេឃុំ
- បទបញ្ជាផ្ទៃក្នុងសហគមន៍ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដី និងយន្តការដោះស្រាយជម្លោះ
- ផែនទីបឋមដែលបង្ហាញអំពីទីតាំង ទំហំ និងព្រំប្រទល់របស់ដីសហគមន៍
- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

- លិខិតពីប្រធានគណៈកម្មាធិការសហគមន៍ ដែលអនុញ្ញាតឲ្យមានការផ្ទេរតួនាទីពីប្រធានទៅឲ្យអនុប្រធាន នៅក្នុងករណីដែលប្រធានមិនអាចបំពេញភារកិច្ចបាន

នៅពេលដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានវាយតម្លៃពាក្យស្នើសុំរួចហើយ នោះមន្ទីររៀបចំដែនដី នឹងស្នើសុំទៅអភិបាលខេត្តឲ្យប្រកាសថាជាតំបន់វិនិច្ឆ័យសម្រាប់សហគមន៍។ ប្រសិនបើការគូរផែនទីបឋមទទួលបានការបញ្ជាក់ថាព្រំប្រទល់នៃក្បាលដីត្រូវបានឯកភាព ពីសំណាក់សហគមន៍ជិតខាង (រួមមានអ្នកថែរក្សាការពារដីរដ្ឋ នោះអភិបាលខេត្ត/អភិបាលស្រុកនឹងចេញលិខិតជូនដំណឹងជាសាធារណៈមួយមិនឲ្យលើសពីរយៈពេល ២០ថ្ងៃ មុនកាលបរិច្ឆេទនៃការវាស់វែងដីជាផ្លូវការ។ នៅក្នុងករណីដែលមានពាក្យបណ្តឹងទៅលើផែនទីបឋម នោះផែនទីនោះត្រូវធ្វើការកែសម្រួលម្តងទៀតរហូតដល់រាល់បណ្តឹង និងជម្លោះនានាត្រូវបានដោះស្រាយរួចរាល់។ សេចក្តីសម្រេចស្ថាពរស្តីពីការទាមទារដីដែលបានបង្ហាញនៅលើផែនទីបឋម ស្ថិតនៅក្នុងការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដែលមានប្រធានជាអភិបាលខេត្ត ឬអភិបាលរងខេត្ត។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលរៀបចំសេចក្តីព្រាងលិខិតផ្លូវការមួយទៅកាន់អភិបាលខេត្ត ដោយស្នើសុំឲ្យចេញឯកសារមួយស្តីពីវិធានការការពារបណ្តោះអាសន្ន (IPM) សម្រាប់សហគមន៍ជនជាតិដើមភាគតិច ពីព្រោះថាសហគមន៍បានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ខ្លួនដោយជោគជ័យ ។ ឯកសារនេះមានសារៈសំខាន់ណាស់ ពីព្រោះវាទប់ស្កាត់នូវរាល់ទម្រង់ទាំងអស់នៃសកម្មភាពមកលើដីនៅក្នុងតំបន់ ដោយការពារតំបន់នោះពីការទន្ទ្រានណាមួយរហូតដល់សហគមន៍បានទទួលប័ណ្ណកម្មសិទ្ធិផ្លូវការសម្រាប់ដីរបស់ពួកគេ និងដោយសារនេះគឺជាឯកសារផ្លូវការទីមួយដែលផ្តល់នូវសន្តិសុខកម្មសិទ្ធិក្នុងកម្រិតមួយចំពោះសហគមន៍ជនជាតិដើមភាគតិច។

# ដំណាក់កាលទី៣៖

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## វាស់វែង បិទផ្សាយ អនុបយោគ
## ដើម្បីចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពជូន
## សហគមន៍ជនជាតិដើមភាគតិច

## សេចក្តីផ្តើម

ច្បាប់ភូមិបាលឆ្នាំ ២០០១ បានកំណត់ថា សហគមន៍ជនជាតិដើមភាគតិចថា "ជាក្រុមមនុស្ស ដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព"។ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាពមានលក្ខណៈប្លែកពីការចុះបញ្ជីដីកម្មសិទ្ធិឯកជន ព្រោះជាការចុះបញ្ជីដីទាំងឡាយ (មានប្រាំប្រភេទ) របស់សហគមន៍ជនជាតិដើមភាគតិច ដែលមានចំណែកខ្លះជាដីឯកជនរបស់រដ្ឋ និងចំណែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ។ ដោយការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចមានលក្ខណៈពិសេសជាងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ឬចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ទើបរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៨៣ អនក្របក ចុះថ្ងៃទី០៩ មិថុនា ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

### ១) ក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

ដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចមានពាក់ព័ន្ធនឹងក្រសួងសំខាន់ចំនួនប្រាំដែលក្នុងនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារៈកិច្ចជួយវាស់វែង និងចេញប័ណ្ណជូនសហគមន៍។ ក្រុមការងារចុះបញ្ជីដីត្រូវបានបង្កើត និងអនុវត្តដោយមន្ត្រីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ហើយប្រធានមន្ទីរត្រូវបានតែងតាំងជានាយកចាត់ការកម្មវិធីក្នុងការសម្រេចណែនាំដល់ក្រុមការងារដែលជាមន្ត្រីក្រោមឪវាទ។ ក្រុមការងារ ត្រូវដឹកនាំផ្ទាល់ដោយប្រធាន ឬអនុប្រធាន និងក្រុមការងារបច្ចេកទេសដែលហៅថា មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យជាមន្ត្រីមានសមត្ថភាព។ ដោយឡែកក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចត្រូវបានបង្កើតឡើងដែលមានសមាសភាពពីដប់ទៅដប់ប្រាំរូប និងតែងតាំងតាមការស្នើសុំរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត មកក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ហើយក្រុមការងារនេះបែងចែកជាពីរផ្នែកដូចខាងក្រោមៈ

ក. មន្ត្រីអនុវត្តការងារវាលរួមមានៈ មន្ត្រីផ្សព្វផ្សាយ និងរៀបចំដែនដី មន្ត្រីកំណត់ព្រំ មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ។

ខ. មន្ត្រីការិយាល័យរួមមានៈ មន្ត្រីបញ្ចូលទិន្នន័យ និងមន្ត្រីគូសប្លង់ក្បាលដី។

### ២) សមាសភាពអ្នកពាក់ព័ន្ធក្នុងការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

នៅក្នុងដំណើរការការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច តម្រូវអោយមានភាគីពាក់ព័ន្ធជាច្រើនចូលរួមដែលមានដូចជាៈ

- សហគមន៍ជនជាតិដើមភាគតិចជាអ្នកកាន់កាប់ផ្ទាល់

- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត
- ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ
- អាជ្ញាធរដែនដី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និង សុរិយោដីជាសេនាធិការ និងជាសមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត)
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងមហាផ្ទៃ (ផ្តល់ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គលស្របច្បាប់)
- ក្រសួងបរិស្ថាន (ធ្វើការពិនិត្យ និងអនុម័តលើដីពាក់ព័ន្ធដែនជម្រកសត្វព្រៃ តំបន់ការពារ និងតំបន់ របៀងបរិស្ថាន ។ល។)
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (ធ្វើការពិនិត្យ និងអនុម័តលើដីពាក់ព័ន្ធដីកសិកម្ម ដីព្រៃ សហគមន៍ និងគម្របព្រៃឈើឆ្នាំ ២០០២។ល។)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាំទ្រផ្នែកហិរញ្ញវត្ថុ
- សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ជាអ្នកជួយណែនាំរៀបចំបទបញ្ញាផ្ទៃក្នុងសម្រាប់គ្រប់គ្រង និងប្រើប្រាសដីសហគមន៍តាមប្រពៃណី ទំនៀមទម្លាប់ និងការសម្របសម្រួល ដោះស្រាយវិវាទផ្ទៃ ក្នុងសហគមន៍។

## ៣) **ដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតដើមភាគតចៈ**

**ក្រោយពីបានទទួល និងបានពិនិត្យរួចរាល់នូវពាក្យស្នើសុំចុះបញ្ជីដីសម្ងហាភាពរបស់សហគមន៍ជនជាតិ ដើមភាគតិច នោះការងារដែលត្រូវអនុវត្តរួមមាន៖**

**ជំហានទី ១៖** ការវាស់វែងនិងប្រមូលទិន្នន័យនិយាមការព្រំប្រទល់ដីតាមប្រភេទនៃការប្រើប្រាស់ ការ កំណត់ព្រំ និងការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ

**ជំហានទី ២៖** បិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

**ជំហានទី ៣៖** ការធ្វើកំណត់ហេតុបញ្ចប់ការបិទផ្សាយទិន្នន័យជាសាធារណៈនូវឯកសារវិនិច្ឆ័យ

**ជំហានទី ៤៖** ការប្រជុំជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តដើម្បីសម្រេចលើរបាយការណ៍ស្តី ពីលទ្ធផលនៃការបិទផ្សាយ និងធ្វើសំណើរមកក្រសួងរៀបចំដែនដីដើម្បីសុំចេញប័ណ្ណកម្មសិទ្ធិដី សម្ងហាភាពជូនសហគមន៍ជនជាតិដើមភាគតិច

**ជំហានទី ៥៖** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ធ្វើលិខិតទៅក្រសួងបរិស្ថាន និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្នើសុំការពិនិត្យ និងយល់ស្របទៅលើដីដែលបានដាក់ស្នើសុំចុះ បញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិច។

**ជំហានទី ៦៖** ក្រសួងរៀបចំដែនដីធ្វើលិខិតទៅរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីស្នើ សុំធ្វើអនុបយោគដីដែលបានស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិច ដោយយោងទៅលើ សេចក្តីសំរេចយល់ស្របរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ជំហានទី ៧៖** ចេញប័ណ្ណកម្មសិទ្ធិដីសម្ងហាភាពជូនសហគមន៍ជនជាតិដើមភាគតិច។

## ៤) ការដាក់ពាក្យសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

ប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី ឬតំណាងសហគមន៍ជនជាតិដើមភាគតិចនិមួយៗ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីរបស់សហគមន៍ខ្លួនដែលបានកាន់កាន់ ព្រមទាំងឯកសារផ្សេងៗទៀតដែលត្រូវភ្ជាប់មកជាមួយ (ក្នុងជំហានទី៣ នៃដំណាក់កាលទី២.៥) មកការិយាល័យភូមិបាលស្រុក ឬមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី។ ក្រោយពីបានទទួលពាក្យស្នើសុំចុះបញ្ជី ប្រសិនបើទីតាំង ទំហំ និងព្រំប្រទល់សហគមន៍មានការឯកភាពពី អ្នកជិតខាង អាជ្ញាធររដ្ឋបាល និងមិនមានទំនាស់ ឬមានទំនាស់តែត្រូវបានដោះស្រាយរួចរាល់ហើយ នោះប្រធានមន្ទីរនឹងធ្វើលិខិតស្នើទៅអភិបាលនៃគណៈអភិបាលខេត្តដើម្បីចេញលិខិតបង្កកការទិញ លក់ ផ្ទេរកម្មសិទ្ធិដីក្នុងបរិវេណដែលបានស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិច។ បន្ទាប់មកការិយាល័យភូមិបាលស្រុក ត្រូវលើកសំណើរជូនអភិបាលស្រុក ដើម្បីចេញសេចក្តីជូនដំណឹងជាសាធារណៈក្នុងរយៈពេល២០ថ្ងៃយ៉ាងតិច មុនកាលបរិច្ឆេទចុះកំណត់ព្រំដី វាស់វែងដី និងវិនិច្ឆ័យ។[14] សេចក្តីជូនដំណឹងត្រូវបិទផ្សាយជាសាធារណៈ នៅកន្លែងងាយមើលឃើញដូចជា៖ ទីស្នាក់ការភូមិ សាលាឃុំ ទីប្រជុំជន និងទីតាំងដីដែលសហគមន៍ស្នើសុំក្រោយពីបានបិទផ្សាយរយៈពេល២០ថ្ងៃ ពុំមានការជំទាស់ ឬតវ៉ាទេ នោះមន្ត្រីត្រូវអនុវត្តបន្ត។

## ៥) ការងារវាស់វែង

ក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចធ្វើការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ កំណត់ព្រំ និងវាស់វែងដីសហគមន៍ជនជាតិដើមភាគតិចដែលមានប្រាំប្រភេទដូចតទៅ៖

**ការងារទីវាល៖ ការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ ការកំណត់ព្រំ និងការវាស់វែង**

- ដីលំនៅដ្ឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
- ដីដែលសហគមន៍ប្រកបរបរកសិកម្មតាមបែបប្រពៃណី
- ដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលទទួលស្គាល់ដោយអាជ្ញាធរ ឬពីអ្នកជិតខាង
- ដីព្រៃអារក្ស (សហគមន៍និមួយៗ មិនលើសពី ៧ ហិកតា)
- ដីកប់ខ្មោច (សហគមន៍និមួយៗ មិនលើសពី ៧ ហិកតា)

នៅក្នុងដំណាក់កាលនេះ សហគមន៍ត្រូវចូលរួមបង្ហាញនូវទីតាំង ព្រំប្រទល់ និងទំហំនៃចំណែកដីផ្សេងៗដែលសហគមន៍បានកាន់កាប់ និងកំពុងប្រើប្រាស់ ដល់ក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។[15]

**ការងារការិយាល័យ៖**

[14] *ទម្រង់គំរូទី ២០៖ គំរូសេចក្តីជូនដំណឹងស្តីពីការចុះកំណត់ព្រំ ការវាស់វែង និងការវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិច*

[15] ទម្រង់គំរូទី២១៖ បែបបទនៃការប្រមូលទិន្នន័យ

មន្ត្រីជំនាញត្រូវបញ្ចូលទិន្នន័យដែលប្រមូលបានទៅក្នុងកំព្យូទ័រដើម្បីកសាងបញ្ជីឈ្មោះម្ចាស់ដី និងប្លង់ផែនទីក្បាលដីព្រមទាំងរៀបចំឯកសារដើម្បីពិនិត្យអោយបានត្រឹមត្រូវ និងត្រៀមយកទៅធ្វើការបិទផ្សាយ។

## ៦) ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

ទិន្នន័យដែលប្រមូលបាន មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីនឹងធ្វើសំណើរទៅអភិបាលស្រុក ដើម្បីចេញសេចក្តីជូនដំណឹង ស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិច[16] រយះពេល៣០ថ្ងៃ ដោយគិតទាំងថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សំរាក។

ការបិទផ្សាយរយះពេល៣០ថ្ងៃ ដើម្បីអោយម្ចាសដីសហគមន៍ ស្ថាប័នពាក់ព័ន្ធ និងសមាជិកគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តទាំងអស់ចូលរួមពិនិត្យ និងធ្វើការតវ៉ាករណីមានការខុសឆ្គង។

## ករណីមិនមានការឯកភាពពីអ្នកជិតខាង ឬអាជ្ញាធររដ្ឋបាល

ក្នុងការអនុវត្តន៍នីតិវិធី ជាពិសេសក្នុងដំណាក់កាលបិទផ្សាយជូនដំណឹងជាសាធារណៈរយៈពេល២០ថ្ងៃ មុនចុះការងារវាល កំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ។ បើទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលស្នើសុំចុះបញ្ជីមិនទាន់មានការឯកភាពពីអ្នកជិតខាង ឬពីអាជ្ញាធររដ្ឋបាលគឺត្រូវរៀបចំកិច្ចដំណើរការតាមរយៈយន្តការ និងនីតិវិធីដូចតទៅ៖

- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល លើកសំណើទៅអភិបាលស្រុក ដើម្បីធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ នៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជីដី។
- បន្ទាប់ពីបានទទួលសំណើ អភិបាលស្រុកពិនិត្យ លើកយោបល់ជូនអភិបាលខេត្ត ដែលជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ សុំអោយក្រុមការងារដីរដ្ឋចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីសហគមន៍។
- អភិបាលខេត្តត្រូវចាត់តាំងក្រុមការងារដីរដ្ឋ ប្រសិនបើមិនទាន់បានចាត់តាំងដើម្បីដំណើរការចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីសហគមន៍ដែលសុំចុះបញ្ជីរតាមអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ មាត្រា ៦ និងមាត្រា ៧។

ក្នុងករណីដែលមានសហគមន៍ សមាជិកសហគមន៍ជនជាតិដើមភាគតិចណាមួយរកឃើញកំហុសឆ្គង ឬជំទាស់ទៅនឹងឯកសារវិនិច្ឆ័យដែលកំពុងបិទផ្សាយជាសាធារណៈនោះ នោះសហគមន៍ ឬសមាជិកសហគមន៍ជនជាតិដើមភាគតិចនោះ អាចដាក់ពាក្យប្តឹង ឬស្នើសុំជាលាយលក្ខអក្សរ អោយមន្ត្រីបច្ចេកទេសធ្វើការកែសម្រួល ឬផ្អាកការបិទផ្សាយជាបណ្តោះអាសន្នសិន។

[16] ទម្រង់គំរូទី ២២៖ សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិច

## ៧)ការប្រជុំ និងសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

បន្ទាប់ពីបញ្ចប់ការបិទផ្សាយជាសាធារណៈនូវការវិនិច្ឆ័យ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយដាក់ជូនអភិបាលនៃគណៈអភិបាលខេត្តពិនិត្យ និងសម្រេចលើរបាយការណ៍ និងឯកសារវិនិច្ឆ័យដើម្បីផ្តល់វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច។

ដើម្បីធ្វើការសម្រេចនេះបាន អភិបាលខេត្តត្រូវធ្វើសំណើរទៅនាយករដ្ឋមន្ត្រីតាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្នើសុំអនុបយោគសម្រាប់ប្រទានកម្ម ចំពោះដីលំនៅឋាន និងដីកសិកម្ម ដែលមានទីតាំងស្ថិតនៅក្នុងចំណែកដីសាធារណៈរបស់រដ្ឋ។

## ៨) ការធ្វើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រោយពីបានទទួលលិខិតស្នើសុំធ្វើអនុបយោគ ពីសំណាក់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងធ្វើលិខិតពីរដាច់ដោយឡែកពីគ្នាផ្ញើទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការពិនិត្យ និងយល់ស្របលើសំណើរសុំអនុបយោគដី ដែលសហគមន៍ជនជាតិដើមភាគតិចបានស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិច។ ប្រភេទដីដែលស្នើសុំការពិនិត្យ និងយល់ស្របពីក្រសួងបរិស្ថាន រួមមានដីស្ថិតនៅក្នុងតំបន់អភិរក្សសត្វព្រៃ តំបន់ការពារ តំបន់របៀងបរិស្ថាន។ល។ ឯប្រភេទដីដែលត្រូវស្នើសុំការពិនិត្យ និងយល់ស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមានដីព្រៃសហគមន៍ និងដីកសិកម្ម និងដីគម្របព្រៃឈើឆ្នាំ២០០២។ល។[17]

បន្ទាប់ពីក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទបានឆ្លើយតបទៅនិងលិខិតស្នើសុំការពិនិត្យ និងការយល់ស្របហើយនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ធ្វើលិខិតមួយទៀតទៅកាន់រាជរដ្ឋាភិបាលដើម្បីស្នើសុំអនុបយោគ និងប្រទានកម្មដីរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចតាមការស្នើសុំរបស់សហគមន៍។

## ៩) ការចេញប័ណ្ណកម្មសិទ្ធិ

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រៀបចំបោះពុម្ពវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីសមូហភាព ចុះហត្ថលេខា និងចែកជូនសហគមន៍ដោយមានបញ្ជាក់ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួម ដែលចង្អុលនូវទីតាំង ទំហំ ព្រំប្រទល់ និយាមកានៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព មានបញ្ជាក់ប្រភេទនៃការប្រើប្រាស់ដី និងកំណត់សម្គាល់ផ្សេងៗ។

[17] តាមបទពិសោធន៍នៃការអនុវត្តជាក់ស្តែង ក្រសួងបរិស្ថាននិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតែងតែយល់ស្របទៅនិងសំណើររបស់ក្រសួងរៀបចំដែនដីដែលស្នើសុំធ្វើអនុបយោគដីរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិច លើកលែងតែដីដែលស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិចនោះស្ថិតនៅក្នុងតំបន់អភិរក្សសត្វព្រៃ តំបន់ការពារ តំបន់របៀង តំបន់ព្រៃសហគមន៍ ជាដើម។